# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0128**

## សម្ភាសន៍ជាមួយឈ្មោះ ហាន នាក់ ភេទប្រុស អាយុ៧៩ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានភូមិចាមរអាល

## មុខងារបច្ចុប្បន្នៈ អាចារ្យភូមិ

## ស្រុកកំណើតភូមិព្រៃកោះ ឃុំវត្តអង្គ ស្រុកបន្ទាយមាស ខេត្តកំពត

## សព្វថ្ងៃរស់នៅភូមិថ្មដែកកេះ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ហ៊ិន សុធានី

## ០១:០៦:៥៨

## ៤៣ទំព័រ

ធានី : ថ្ងៃនេះថ្ងៃទី១១ ខែ១២ ឆ្នាំ២០១០ ។ ខ្ញុំឈ្មោះធានីលោកតា ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចុះមកនេះ ខ្ញុំចង់សាកសួរពីប្រវត្តិរបស់លោកផ្ទាល់ លោកតាបានឆ្លងតាំងពីមុនរហូតមកដល់ឥឡូវ ។ ហើយរឿងរ៉ាវអស់នេះ ពួកខ្ញុំសុំអនុញ្ញាតិយករឿងរ៉ាវលោកតាមកធ្វើជាសៀវភៅ ក៏ដូចជាឲ្យអ្នកសិក្សា ឬក៏ក្មេងៗក្រោយបានរៀន បានសូត្រដឹងពីរឿងរ៉ាវអស់ហ្នឹង លោកតាណា៎ ។

នាក់ : បាទៗ ។

ធានី : ជាដំបូងខ្ញុំសុំសួរលោកតាឈ្មោះអីគេ?

នាក់ : ខ្ញុំឈ្មោះ ហាន នាក់ ។

ធានី : ហាន នាក់?

នាក់ : ហ៎ា ហា ។

ធានី : ឆ្នាំហ្នឹងអាយុប៉ុន្មានហើយ?

នាក់ : ៧៩ ។

ធានី : ៧៩ លោកតាមានស្រុកកំណើតនៅណាវិញ?

នាក់ : នៅខេត្តកំពត ។

ធានី : ភូមិឃុំអីដែរ?

នាក់ : ភូមិព្រៃកោះ ឃុំវត្តអង្គ ស្រុកបន្ទាយមាស ខេត្តកំពត ។

ធានី : ចឹងលោកតាសព្វថ្ងៃនៅរស់ណាដែរៗ?

នាក់ ៖ រស់នៅភូមិថ្មដែកកេះ ឃុំបន្ទាយឆ្មា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ឪពុកលោកតាឈ្មោះអីគេ?

នាក់ ៖ ឈ្មោះហាន ។

ធានី ៖ អីគេហាន?

នាក់ ៖ ហ៉េ! អត់ៗស្គាល់ ឈូកៗ ។

ធានី ៖ ឈូក ហាន ។ គាត់នៅរស់ទេ?

នាក់ ៖ ស្លាប់ហើយ ។

ធានី ៖ ស្លាប់នៅពេលណា?

នាក់ ៖ ស្លាប់នៅសម័យមុនឥស្សរៈទៀត ។

ធានី ៖ ឆ្នាំប៉ុន្មានលោកតា?

នាក់ ៖ ប្រហែលឆ្នាំ ទេ!មិនដឹងឆ្នាំប៉ុន្មានទេ មុនឥស្សរៈទៀត ។

ធានី ៖ សម័យបារាំង?

នាក់ ៖ សម័យបារាំង ។

ធានី ៖ សម័យបារាំង ។ អឺ! ចុះម្តាយ?

នាក់ ៖ ម្តាយស្លាប់មុនឪពុក ។

ធានី ៖ ម្តាយឈ្មោះអីគេ?

នាក់ ៖ ឈ្មោះអឺ! ឡុង ។

ធានី ៖ អីគេឡុង?

នាក់ ៖ អ៊ុង ឡុង ។

ធានី ៖ អ៊ុង ឡុង គាត់ស្លាប់មុនឪពុក ។ លោកតាមានបងប្អូនប៉ុន្មាននាក់?

នាក់ ៖ ខ្ញុំមាន៦នាក់ ។

ធានី ៖ នៅរស់ទាំងអស់ទេ?

នាក់ ៖ នៅរស់អឺ! ១ ២ នៅរស់៣ ។

ធានី ៖ អឺ! ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

នាក់ ៖ ប្រុស២ ប៉ុនស្លាប់ហើយនៅតែខ្ញុំ ។

ធានី ៖ ប្រុស២?

នាក់ ៖ បាទ! ស្រី៤ ប៉ុនស្រីស្លាប់អស់ហើយនៅសល់តែ១ទេ ។

ធានី ៖ ចឹងស្លាប់ស្រី៣ ប្រុស១?

នាក់ ៖ បាទ!

ធានី ៖ ចឹងនៅសល់តែប្រុស១ ស្រី១?

នាក់ ៖ បាទៗ ។

ធានី ៖ លោកតារៀបគ្រួសារឆ្នាំប៉ុន្មាន?

នាក់ ៖ ឆ្នាំ ឈប់សិន ឆ្នាំ៨៧ ។

ធានី ៖ ៨៧?

នាក់ ៖ អានេះគ្រួសារក្រោយ ។

ធានី ៖ ចុះគ្រួសារមុន?

នាក់ ៖ គ្រួសារមុនយូរហើយតាំងពីឆ្នាំ៦២នោះ ។

ធានី ៖ អូ! ១៩៦២?

នាក់ ៖ បាទ!

ធានី ៖ ៨៧ហ្នឹងឈ្មោះអីគេគ្រួសារ?

នាក់ ៖ ពិន ស៊ីវន ។

ធានី ៖ ពិន ស៊ីវន មានកូនប៉ុន្មាននាក់?

នាក់ ៖ មានកូន២ ។

ធានី ៖ ចុះដល់ពេលគ្រួសារមុនឈ្មោះអីគេ?

នាក់ ៖ គ្រួសារ អឺ!សំ ទាប ។

ធានី ៖ សំ ទាប?

នាក់ ៖ បាទ!

ធានី ៖ ហើយគាត់មានកូនអត់ ដែលអត់ទេ?

នាក់ ៖ កូន៦ហ្នឹង ។

ធានី ៖ កូន៦នាក់?

នាក់ ៖ កូន៦នាក់ ។

ធានី ៖ កូន៦នាក់ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

នាក់ ៖ អឺ! ប្រុស៣ មើលប្រុស ។

ធានី ៖ បងប្អូនលោកតាមាន៦នាក់ ដល់កូនលោកមាន៦នាក់ដែរ?

នាក់ ៈ បាទ!

ធានី ៈ ចង់សួរបញ្ជាក់កន្លែងហ្នឹង ។

នាក់ ៈ មើលប្រុសនៅម៉ាខ្សែ១ នៅអន្លង់វែង១ នៅនេះ១ ប្រុស៣ ។

ធានី ៈ ប្រុស៣ ស្រី៣?

នាក់ ៈ ស្រី៣ ។

ធានី ៈ នៅទាំងអស់លោកតានោះ?

នាក់ ៈ នៅទាំងអស់ ខ្វះស្លាប់ ។

ធានី ៈ ហើយគ្រួសារលោកតានៅរស់ដែរ សំ ទាប?

នាក់ ៈ ស្លាប់មុនយូរហើយ ស្លាប់តាំងពីឆ្នាំ៩៨នោះ ។

ធានី ៈ ៩៨នោះ ទើបស្លាប់ឥឡូវទេ ។ ចឹងលោកតារៀនបានថ្នាក់ទីប៉ុន្មានដែរ?

នាក់ ៈ ខ្ញុំ អានេះប្រវត្តិខ្ញុំពិបាកប្រាប់ណាស់ ប្រវត្តិខ្ញុំរៀនថ្នាក់អន់បំផុតហើយ ប៉ុនខ្ញុំបួស ខ្ញុំបាន រៀនសាលាបាលី ។

ធានី ៈ បួសនៅវត្តណា?

នាក់ ៈ នៅវត្តពញាអង្គរ ។

ធានី ៈ ពញាអង្គរ?

នាក់ ៈ បាទ!

ធានី ៈ នៅណាវិញលោកតា?

នាក់ ៈ នៅខេត្តកំពត ។

ធានី ៈ ស្រុកអីដែរ កាលហ្នឹង?

នាក់ ៈ ភូមិព្រៃកោះ ឃុំវត្តអង្គ ស្រុកបន្ទាយមាស ខេត្តកំពត ។

ធានី ៈ អូ! ចឹងវត្តហ្នឹងវត្តពញាអង្គរហ្នឹង គឺនៅកន្លែងភូមិលោកតានៅហ្នឹង?

នាក់ ៈ នៅកន្លែងខ្ញុំនៅហ្នឹង ។

ធានី ៈ អឺ! ចឹងលោកតាបួសបានប៉ុន្មានវស្សាដែរ?

នាក់ ៈ បាន៤ ។

ធានី ៈ ៤វស្សា ហើយលោកតាទៅណាទៀតទៅ សឹកទៅណា?

នាក់ ៈ សឹកហ្នឹង កាលជំនាន់នោះវារកទីដៅមិនឃើញ ដើរតែពាសទៅនៅកំពង់ចាម ទៅនៅចំការកៅ ស៊ូតែពាស វាគ្មានគោលដៅ ។

ធានី ៖ ម៉េចចឹងតា?

នាក់ ៖ ចុះចេះដើរៗទៅ អាងតែខ្លួនមួយចេះដើរទៅ សោត់សែងត្រែង ។

ធានី ៖ កាលពេលបួសហ្នឹង បួសនៅឆ្នាំប៉ុន្មាន?

នាក់ ៖ បួសនៅឆ្នាំ៨២ ។

ធានី ៖ អូ! ១៩៨២?

នាក់ ៖ បាទ!

ធានី ៖ ក្រោយពីបួសទៅ ដើរលេង ឬក៏ទៅណា?

នាក់ ៖ ដើរទៅស៊ីឈ្នួលគេ ។

ធានី ៖ ដើររកស៊ី?

នាក់ ៖ បាទ! ដើរៗរកស៊ី ។

ធានី ៖ ទៅខេត្តណាខ្លះទៅ?

នាក់ ៖ ទៅកំពង់ចាម មកនៅកំពតហ្នឹង ហើយទៅនៅស្រុកទៅនៅបៀតភ្នំដិន បៀតស្រុក ។

ធានី ៖ ភ្នំដិន តាកែវ?

នាក់ ៖ អឺ! តាកែវ ដើរទៅស៊ីឈ្នួល ដួលព័ទ្ធគេ ។

ធានី ៖ ហើយម៉េចទៀតតា?

នាក់ ៖ បាទ!

ធានី ៖ ម៉េចទៀត ក្រៅពីការស៊ីឈ្នួល ហើយធ្វើអីទៀត?

នាក់ ៖ ស៊ីឈ្នួល ដល់ចប់ស៊ីឈ្នួលចឹងមក មកយកគ្រួសារ ។

ធានី ៖ មកយកគ្រួសារនៅឆ្នាំ៦២?

នាក់ ៖ ឆ្នាំ៦២ហ្នឹង ។

ធានី ៖ ចា៎!គ្រួសារនៅឆ្នាំ៦២ ។ ចឹងគ្រួសាររៀបការនៅណា នៅភូមិយើងដដែលឬក៏យ៉ាងម៉េច?

នាក់ ៖ នៅភូមិព្រៃខ្លុត ឃុំព្រៃត្រឡាច ស្រុកមោង ខេត្តបាត់ដំបង ។

ធានី ៖ ចឹងគ្រួសារលោកពូនៅស្រុកកំណើតនៅហ្នឹង ហើយចំការនៅហ្នឹង?

នាក់ ៖ ស្រុកកំណើតសុទ្ធនៅឯកំពតនោះ ប៉ុនមកជួបជុំគ្នានៅ ។

ធានី ៖ អូ! នៅ....?

នាក់ ៖ ហ្នឹងនៅម្ដុំ ។

ធានី ៖ ចឹងអ្នករកស៊ីដូចគ្នា?

នាក់ ៖ អ្នករកស៊ីដូចគ្នា ។

ធានី ៖ ហើយរៀបការនៅហ្នឹង ។ ចឹងឪពុកម្តាយនៅជុំគ្នាដែរ?

នាក់ ៖ ឪពុកម្តាយអត់ទេ ។

ធានី ៖ រៀបការខ្លួនឯង?

នាក់ ៖ ស្លាប់បាត់អស់ហើយ ។

ធានី ៖ ហើយម៉េចទៀត លោកតាក្រោយរៀបការហើយ ទៅណាទៅណែ?

នាក់ ៖ ក្រោយរៀបការហ្នឹង អត់មានដើរទៅណាទេ គិតរកស៊ីហើយ ។

ធានី ៖ រកស៊ីនៅស្រុកមោងហ្នឹង?

នាក់ ៖ ហ្នឹងហើយ ធ្វើស្រែចំការ ។

ធានី ៖ ម៉េចទៀតលោកតា ធ្វើស្រែចំការហើយ?

នាក់ ៖ ធ្វើស្រែចំការហើយដល់មកឆ្នាំ កើតខ្មែរក្រហមនៅភ្នំវ៉ៃចាបនេះ អាហ្នឹងអាប៉ះអាប៉ើកហើយ ដល់មក ។

ធានី ៖ ឆ្នាំប៉ុន្មាន កើតខ្មែរក្រហមចូល?

នាក់ ៖ មិនដឹងឆ្នាំប៉ុន្មានទេ ។

ធានី ៖ ព្រោះ៦២?

នាក់ ៖ មុនៗសង្គ្រាមលន់ នល់ ។

ធានី ៖ មុនៗសង្គ្រាមលន់ នល់ វាក្នុង៦០ជាងដែរ?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ៦៣ ៦៤?

នាក់ ៖ ៦៨ ។

ធានី ៖ ៦៨?

នាក់ ៖ ហ្នឹងហើយ កាលហ្នឹងខ្ញុំ ។

ធានី ៖ ១៩៦៨ ម៉េចលោកតា?

នាក់ ៖ ៦៨ហ្នឹង ខ្ញុំគេឲ្យមកវ៉ៃខ្មែរក្រហមនៅភ្នំវ៉ៃចាប ។

ធានី ៖ ចា៎! លោកតា ចឹងចូលបដិវត្តតាំងពីពេលណាមក?

នាក់ ៖ ចូល ។

ធានី ៖ អេ៎!វ៉ៃខ្មែរក្រហមតើ?

នាក់ ៖ វៃខ្មែរក្រហមនៅភ្នំវៃចាប ។

ធានី ៖ ភ្នំវៃចាប?

នាក់ ៖ បាទ!

ធានី ៖ ម៉េចទៀតតា?

នាក់ ៖ ដល់ហើយចប់ពីហ្នឹងទៅ ខ្មែរក្រហមវាសាបសូន្យទៅវាកើតសង្គ្រាមលន់ នល់ ។

ធានី ៖ ចាំ!លន់ នល់៧០?

នាក់ ៖ បាទ!

ធានី ៖ ១៩៧០?

នាក់ ៖ ហ្នឹងហើយ ដល់កើតសង្គ្រាមលន់ នល់ចប់ចឹងមក ហើយដល់ហ្នឹងសង្គ្រាមលន់ នល់ សង្គ្រាម ជាមួយសម្តេចឪ សង្គ្រាមជាមួយសម្តេចឪ ដល់ចប់ចឹងមកបានចូលមកខ្មែរក្រហម ។

ធានី ៖ អូ! ខ្មែរក្រហម?

នាក់ ៖ បាទ!

ធានី ៖ កាលពេលនៅសង្គ្រាមដែលលោកតាថានៅភ្នំវៃចាប លោកតាធ្វើអីគេបានលោកតាធ្វើអីគេ បានទៅវៃខ្មែរក្រហមនៅហ្នឹង?

នាក់ ៖ ខ្ញុំប្រជាជន ។

ធានី ៖ ម៉េចបានគេឲ្យទៅវៃនៅហ្នឹង?

នាក់ ៖ គេកេណ្ឌកៀរឲ្យទៅវៃ ។

ធានី ៖ កេណ្ឌ?

នាក់ ៖ បាទ!

ធានី ៖ ភ្នំវៃចាបហ្នឹងនៅណាវិញ?

នាក់ ៖ ភ្នំវៃចាបនៅខេត្តបាត់ដំបង ។

ធានី ៖ ខេត្តបាត់ដំបងគេឲ្យទៅវៃ ប៉ុន្មាននាក់ដែលគេព្រមទៅកេណ្ឌហ្នឹង ម៉េចបានគេឲ្យធ្វើចឹង?

នាក់ ៖ ទេ! មកពីព្រៃខ្លូតស្រុកមោងហ្នឹងមកវៃហ្នឹង ប៉ុនអត់មានស្អីគេ មកដៃទទេរ កាំបិត ពូថៅ ។

ធានី ៖ ហើយខ្មែរក្រហម វៃជាមួយខ្មែរក្រហមឈ្នះដែរ?

នាក់ ៖ ទេ! គេក៏ខ្លាចយើង យើងក៏ខ្លាចគេ វាឃើញយើងទៅច្រើន គេភៀសខ្លួនបាត់ទៅអត់បាន ជួបគ្នាទេ ។

ធានី ៖ អូ! ចឹងយើងបានជោគជ័យ?

នាក់ ៖ បាទ!

ធានី ៖ យើងបានទៅដល់ភ្នំវៃចាបហ្នឹងដែរ?

នាក់ ៖ បាទ! ហ្នឹងហើយអត់មានបានវៃគ្នា បាញ់គ្នាទេ សុទ្ធតែកាំបិទពូថៅដូចគ្នា ។

ធានី ៖ អ្នកណាគេអ្នកផ្ដើមឲ្យទៅវៃចឹង?

នាក់ ៖ ផ្ដើមកាលហ្នឹងជំនាន់ ទេ!ជំនាន់សម្ដេចឪ ។

ធានី ៖ អ្នកណាគេ ឈ្មោះអីគេដែលអ្នកនាំទ័ពលោកតាទៅវៃនៅហ្នឹង?

នាក់ ៖ ឈ្មោះមេកងយុទ្ធ ។

ធានី ៖ មេកងយុទ្ធ ។

នាក់ ៖ មេកងយុទ្ធនៅភូមិព្រះអណ្ដូង ។

ធានី ៖ អូ! លោកតាចាំទាំងអស់?

នាក់ ៖ បាទ!

ធានី ៖ ព្រះអណ្ដូង ឃុំអីគេ?

នាក់ ៖ ឃុំព្រះអណ្ដូង ស្រុកមោងឫស្សី ។

ធានី ៖ ជាអ្នកនាំលោកតាទៅវៃ តាយុទ្ធហ្នឹង?

នាក់ ៖ បាទ!

ធានី ៖ គេហៅមេកងចឹង?

នាក់ ៖ បាទ!

ធានី ៖ ចាំ! បន្ទាប់មកទៀតខ្មែរក្រហមក៏រត់បាត់ទៅ?

នាក់ ៖ រត់បាត់ទៅ ។

ធានី ៖ នៅឆ្នាំ៧០ មានសង្គ្រាមម្ដងទៀត លោកតាធ្វើអីគេ?

នាក់ ៖ ខ្ញុំអត់មានធ្វើស្អីទេ ។

ធានី ៖ ពេលហ្នឹងនៅផ្ទះ?

នាក់ ៖ នៅផ្ទះស្អីក៏មិនធ្វើៗ កាំភ្លើងក៏មិនដែលលីហ្នឹងគេ ។

ធានី ៖ ចាំៗ ហើយម៉េចទៀតទៅ?

នាក់ ៖ ហើយដល់មកសង្គ្រាមលន់ នល់ចប់ ចូលសង្គ្រាមខ្មែរក្រហម បានសម្ដេចលោកស្រែកថាកូនចៅចូលព្រៃម៉ាគីស៊ីដេះ ស៊ីធ្យូង ក៏ចូលព្រៃអស់ទៅ ។

ធានី ៖ អឺ! លោកតាចូលដែរ?

នាក់ ៖ ចូល ។

ធានី ៖ ចូលឆ្នាំប៉ុន្មាន ចាំទេ?

នាក់ ៖ ចូលឆ្នាំ៧០ ប៉ុន្មានទេ ។

ធានី ៖ ៧២ ៧៣?

នាក់ ៖ ដូច៧២ ។

ធានី ៖ ៧២?

នាក់ ៖ បាទ!

ធានី ៖ ៧២ ចូលទៅព្រៃខាងណា?

នាក់ ៖ ចូលទៅព្រៃខាងនៅខាងព្រៃខ្ជូតហ្នឹង ។

ធានី ៖ ព្រៃខ្ជូត?

នាក់ ៖ ព្រៃខ្ជូត ឃុំព្រៃត្រឡាចហ្នឹង ។

ធានី ៖ ទៅដល់ជួបអ្នកណាគេខ្លះទៅ?

នាក់ ៖ ទៅដល់អត់មានជួបគេឯងទេ សុទ្ធតែគ្នាយើងទាំងអស់ ដែលរត់ទៅជាមួយគ្នាហ្នឹង ។

ធានី ៖ អូ! នៅក្នុងភូមិយើងហ្នឹង?

នាក់ ៖ នៅក្នុងភូមិហ្នឹង ។

ធានី ៖ អូ! អ្នកភូមិយើងរត់ទៅព្រៃទាំងអស់?

នាក់ ៖ រត់ៗទៅព្រៃទាំងអស់ ។

ធានី ៖ ហើយមានអ្នកណាអ្នកដឹកនាំពេលហ្នឹងទេ?

នាក់ ៖ ទេ! អ្នកដឹកនាំវាមានមេក្រុមមេអីចឹងដែរ តែអត់ថាឥឡូវយើងចូលព្រៃទាំងអស់គ្នា រៀបចំកាន់អាវុធ កាន់អីតៗទល់សព្វបែបសព្វយ៉ាង គេឡើងបំផុសបំផុល គេទៅតាមគេ ប៉ុន្តែខ្ញុំអត់មាន កាន់អីហ្នឹងគេទេ ។

ធានី ៖ ចាំ! ហើយអ្នកណាអ្នកបំផុសបំផុលហ្នឹង លោកតាដឹងទេ?

នាក់ ៖ ទេ! ឈ្មោះហ្នឹងវាភ្លេចអស់ហើយ វាយូរពេកហើយ វាជាង៧០ឆ្នាំ យូរភ្លេចអស់ហើយ ។

ធានី ៖ កាលហ្នឹងលោកតាអាយុប៉ុន្មានដែរ?

នាក់ ៖ ខ្ញុំអាយុជិត៣០ ។

ធានី ៖ ថា២៩ចុះលោកតានោះ?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ អាយុ២៩ចូលបដិវត្តនៅឆ្នាំ៧២ នៅព្រៃខ្ចូត ។ ហើយលោកតានៅក្នុងព្រៃហ្នឹងធ្វើអីគេទៅ?

នាក់ ៖ អត់មានធ្វើអីទេ ។

ធានី ៖ នៅជាប្រជាជនធម្មតា?

នាក់ ៖ នៅជាប្រជាជនធម្មតា គេធ្វើស្រែធ្វើហ្នឹងគេ ។

ធានី ៖ ធ្វើស្រែក្នុងព្រៃហ្នឹង?

នាក់ ៖ ទេ! ដល់ធ្វើស្រែយើងលបមកធ្វើស្រែយើងមក ។

ធានី ៖ ភូមិយើងមក?

នាក់ ៖ ភូមិយើងមក ។

ធានី ៖ ដល់ពេលគេត្រូវការប្រើអី?

នាក់ ៖ ត្រូវការប្រើអីអាហ្នឹងគេប្រើទៅ ប៉ុនមានគេយាម ឈ្លបគេតាំងឈ្លបឲ្យយាម បើថាយើងធ្វើស្រែហ្នឹង នោះគេយាមឆ្ងាយនោះ ។

ធានី ៖ គេយាមចឹងធ្វើអី?

នាក់ ៖ គេយាមកុំឲ្យពួកខ្មាំងមកលុកលុយ អត់បានធ្វើស្រែចំការ គេការពារ ។

ធានី ៖ ចឹង?

នាក់ ៖ បាទ!

ធានី ៖ ចឹងលោកតាអ្នកធ្វើតែស្រែទេ?

នាក់ ៖ បាទ!

ធានី ៖ ហើយគេមានបញ្ជាឲ្យយើងធ្វើអីផ្សេងក្រៅពីស្រែ?

នាក់ ៖ ទេ! គេអត់មានឲ្យធ្វើអី គេឲ្យបិទចំរូងបិទអីយកទៅចាក់ ។

ធានី ៖ អូ! លោកតាអ្នកបិទចំរូង?

នាក់ ៖ បាទ! ខ្ញុំអង្គុយបិទចំរូងក្នុងម៉ោថ្ងៃគេយក១០០ ឬ២០០ចំរូង អង្គុយបិទឲ្យគេទៅ ។

ធានី ៖ ហើយកាលហ្នឹងដឹងថាគេចូលបដិវត្តហ្នឹង ចូលធ្វើអី?

នាក់ ៖ ទេ! ខ្ញុំ ។

ធានី ៖ ចុះនឹកឃើញម៉េច ចូលនឹងគេ?

នាក់ ៖ ខ្ញុំគេ ចុះគេទៅអស់ហើយ យើងនៅម្នាក់ឯងកើត ដល់យើងទៅទាំងអស់គ្នា ។

ធានី ៖ យើងនាំគ្នាទៅ?

នាក់ ៖ បានទៅទាំងអស់គ្នា ហើយបើយើងនៅតែឯង មិនហ៊ាននៅ ។

ធានី ៖ អត់មានថាទីងចិត្តរឿងលន់ នល់ធ្វើអីៗអត់ទេ?

នាក់ ៖ អត់ទេ ។

ធានី ៖ ឃើញគេទៅនាំគ្នាទៅ?

នាក់ ៖ អត់ទេ នាំគ្នាទៅ សម្ដេចស្រែកថាកូនចៅចូលព្រៃម៉ាក់គី ស៊ីផេះស៊ីធ្យូងបានរស់ ហើយក៏នាំគ្នាទៅៗ ។

ធានី ៖ លោកតាស្ដាប់ពាក្យសម្ដេចចឹងហ៎?

នាក់ ៖ បាទៗ ។

ធានី ៖ ចុះលោកតា ដល់៧៥លោកតាទៅណាទៅ?

នាក់ ៖ ៧៥ ពេញសម័យ៣ឆ្នាំហ្នឹង ពេញ ។

ធានី ៖ ចា៎! ពេលហ្នឹងលោកតានៅក្នុងព្រៃទៀត ឬក៏ម៉េច?

នាក់ ៖ ខ្ញុំ អត់ទេខ្ញុំ ៧៥ខ្ញុំនៅព្រៃខ្ជូត ប៉ុនគេបញ្ជូនខ្ញុំឲ្យមកនៅកាន់កាប់នៅភូមិចាមរអាលនេះ ។

ធានី ៖ អូ! កាន់កាប់ភូមិចាមរអាល ចឹងលោកតាធ្វើមេភូមិ?

នាក់ ៖ ខ្ញុំគេៗបញ្ជូនមកឲ្យទទួលអ្នកភ្នំពេញ ។

ធានី ៖ ចា៎! ប៉ុន្តែលោកតាធ្វើជាមេភូមិ ដើម្បីទទួលប្រជាជនអ្នកភ្នំពេញមក មែនទេ?

នាក់ ៖ មិនមានមេភូមិទេ ដូចជាមេកងមេអីនោះណា៎ ។

ធានី ៖ ចុះមេភូមិគេឈ្មោះអីចុះ?

នាក់ ៖ ហ៎! មិនដឹងឈ្មោះអីទេ ។

ធានី ៖ មិនមែនលោកតាទេ?

នាក់ ៖ មិនមែនទេ ខ្ញុំពីក្រោមបន្ទាប់គេ ។

ធានី ៖ ចឹងលោកតានៅទៅកាន់កាប់នៅភូមិចាមរអាលហ្នឹង ទទួលអ្នក១៧មេសា?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ហើយម៉េចទៀតទៅលោកតា?

នាក់ ៖ ដល់នៅបានប្រហែលជា៣-៤-៥ខែ គេឲ្យខ្ញុំទៅចាត់ឲ្យខ្ញុំធ្វើប្រធានការដ្ឋាន ។

ធានី ៖ បានប៉ុន្មានខែ៣-៤-៥ខែ ហើយប៉ុន្មានខែ ៤ទៅ៥ខែ?

នាក់ ៖ បាទ! ប្រហែល៤-៥ខែ ។

ធានី ៖ ៤ទៅ៥ខែ?

ណាក់ ៖ បាទ! ឲ្យខ្ញុំធ្វើប្រធានការដ្ឋាន ។

ធានី ៖ ធ្វើប្រធានការដ្ឋាន១អីគេ?

ណាក់ ៖ សម្រាប់មើលការខុសត្រូវបងប្អូនមកពី១៧ហ្នឹង ឲ្យស៊ីឲ្យចុកបុកទំពារអី កាលហ្នឹងមិនទាន់តឹងរឹង មិនទាន់ដាច់បាយទេ ។

ធានី ៖ ១៧មេសា ហូបចុក ការរស់នៅចឹង?

ណាក់ ៖ បាទ!

ធានី ៖ ហើយចឹងលោកតា ពេលដែលឃើញ ពេលដែលលោកតាទៅទទួលអ្នក១៧មេសាដំបូងយ៉ាងម៉េចដែរ?

ណាក់ ៖ វាដំបូងវាអត់អីទេ មក ។

ធានី ៖ ចូលមកដល់យ៉ាងម៉េច ឃើញប្រជាជន ពួកគាត់យ៉ាងម៉េច?

ណាក់ ៖ ចូលមកដល់ប្រជាជនគេនៅហ៊ឹហានៅឡើយទេ ដល់ពេលនៅយូរ បានប្រហែលម៉ាខែ ២ខែហ្នឹងបានគេរកធ្វើខ្ទមធ្វើអីរគេរតូចនៅ ដល់នៅបានឆ្នាំ៧៥ ដល់នៅបានប្រហែល២-៣ខែអាហ្នឹងគេចាប់ផ្ដើមបន្ថត់បាយហើយ ។

ធានី ៖ បន្ថត់បាយ ម៉េចចទៀតតា?

ណាក់ ៖ ចាប់ផ្ដើមបន្ថត់បាយ ។ ដល់ចាប់បន្ថត់បាយចឹងប្រជាជនចេះលួច ចេះដើររត់ចេញ ដើរបេះដើរបោចស៊ីគល់ចេកគល់ល្ហុងអី សព្វបែបសព្វយ៉ាងទៅ ស្លឹកឈើស្លឹកព្រៃទៅចេះតែស៊ី ។ ហើយដល់អាស៊ីតិចវាឈឺទៅយកទៅពេទ្យផាប់គរដៃជើងគ្នា ។

ធានី ៖ ម៉េចទៀតតា?

ណាក់ ៖ ដល់ពេលគេបន្ថត់បាយ ប្រជាជនកាន់តែផាប់ច្រើនហើយ ហើយខ្ញុំហ្នឹងក៏គ្មានបាយស៊ីដែរ ខ្ញុំគ្រាន់តែមេកងខាងសេដ្ឋកិច្ចហ្នឹងគេ ដែលប្រធានកាគុមប៉ៃវាអី!ប្រធានសហករណ៍១ឈ្មោះ ណេង ។

ធានី ៖ ណេង?

ណាក់ ៖ បាទ!

ធានី ៖ ម៉េចលោកតា គាត់ហ្នឹងមកពីណាវិញ ណេងហ្នឹង?

ណាក់ ៖ គាត់ហ្នឹងនៅស្រុកហ្នឹងគ្នាហ្នឹង ។

ធានី ៖ ជាមួយលោកតាដែរ?

នាក់ ៖ ជាមួយគ្នាហ្នឹង នៅរួមរស់ជាមួយគ្នា ប៉ុនគេធ្វើប្រធានសហករណ៍ហ្នឹង ។ ហើយក៏ខ្ញុំគេចាត់ឲ្យខ្ញុំទៅធ្វើស្រែនៅបឹងឫស្សីរំលេងនេះ ហើយអត់បាយអត់ទឹក ខ្ញុំគ្រុន៨ខែ ក្បាលជន្គង់អន្ទុយទៅខ្ពស់ជាងក្បាល គ្មានស្អីស៊ីទេ ។

ធានី ៖ ម៉េចទៀតតា?

នាក់ ៖ ដល់ចាប់ពីធ្វើស្រែហ្នឹងមក អាហ្នឹងចាប់ៗផ្ដើមគេរួមធ្វើស្រែប្រាំងហើយ នៅពោន នៅភូមិពោនហ្នឹង ។ ធ្វើស្រែប្រាំងហ្នឹងបានមក ក៏យកមកចែកចាយគ្នាស៊ីតិចតួចចឹងទៅ ហើយក៏កើត សហករណ៍គ្រប់ភូមិទាំងអស់ ។ ដល់ហ្នឹងគេចាប់ផ្ដើមហើយ គេរកប្រជាជនសោៗ ភឹមៗ គេ ស្រាវជ្រាវទៅគេយកទៅសម្លាប់ទាំងអស់ យួនវៀន់នៅក្រឡុងក្រលាតគ្រង់ណាគេយកទៅ សម្លាប់ទាំងអស់ អាហ្នឹងដល់ពេលសម្លាប់ណា ។ សម្លាប់អស់ យួនចឹងទៅ គេរកពួកទាហាន សោ ភឹមហ្នឹង ។ កាលហ្នឹងទាហានសោ ភឹម មិន!ប្រឆាំងជាមួយយើងនៅព្រំៗដែននោះ ។ ហើយរកទៅឲ្យស៊ើបអង្កេត អាណាទាហាន អាណាពាក់សក្តិ១ សក្តិ២អីហ្នឹង គេយកទៅវៃចោលទាំងអស់ នៅចាមរអាលហ្នឹង គេធ្វើបាយទាំងខ្ទះៗ កាប់គោ កាប់អីស្ងួរឲ្យស៊ីហ្នឹង ដឹកមកទាំងឡានៗយកមកដល់ វៃចោលនឹងកោះក្រឡ មោងនេះ ។ មកដល់ដាក់តំរៀបគ្នាផ្ទុំបេ បាញ់ចោល កាយកប់ទាំងអស់ទៅ ។

ធានី ៖ ប្រជាជននៅចាមរអាលហ្នឹង?

នាក់ ៖ បាទ! នៅចាមរអាល នៅព្រៃខ្ពួតហ្នឹង គេជ្រើសរើសអ្នកមានបណ្ដាសក្តិ ដូចសក្តិ១ សក្តិ២ ត្រឹមអាសឹងង់ហ្នឹង គេយកទៅសម្លាប់អស់ហើយ ។

ធានី ៖ យកទៅសម្លាប់នៅណាមិញ លោកតានិយាយ?

នាក់ ៖ សម្លាប់នៅកោះក្រឡនេះ ។

ធានី ៖ កោះក្រឡ កន្លែងណាទៅកោះក្រឡ?

នាក់ ៖ កោះក្រឡហ្នឹង យុំអី! ។

ធានី ៖ អត់ទេ! ចង់និយាយថាសម្លាប់កន្លែងណានៃកោះក្រឡ ភូមិកោះក្រឡហ្នឹង?

នាក់ ៖ នៅភូមិកោះក្រឡហ្នឹងខ្ញុំមិនដឹងទេ តែថាយកមកកន្លែងនឹងសម្លាប់នៅព្រៃកោះក្រឡហ្នឹង ។

ធានី ៖ ខាងណាភូមិ?

នាក់ ៖ មិនដឹង បើខ្ញុំនៅនោះខ្ញុំមិនដឹងដែល ។

ធានី ៖ ម៉េចបានលោកដឹងរឿងហ្នឹង?

នាក់ ៖ ខ្ញុំចេះដឹងដល់ខ្ញុំចេះសួរគេ ។

ធានី ៖ សួរអ្នកណា?

នាក់ ៖ សួរដែលអ្នកនាំ ដូចថាពួកទាហានៗដែលនាំទៅហ្នឹង ថា "ដឹកយកទៅណាច្រើនម៉េច?" "អឺ! យកទៅវ៉ៃចោលនៅកោះក្រឡ" ។

ធានី ៖ ស្គាល់ឈ្មោះគាត់ទេ អ្នកប្រាប់លោកតាហ្នឹង?

នាក់ ៖ ភ្លេចអស់ហើយ ។

ធានី ៖ អាហ្នឹងគេហៅអីយោធាគេ?

នាក់ ៖ ហ្នឹងហើយពួកយោធា ។

ធានី ៖ យោធាអីគេ យោធាឃុំ ស្រុក តំបន់?

នាក់ ៖ យោធាតំបន់ ។

ធានី ៖ យោធាតំបន់ៗប៉ុន្មានកាលហ្នឹង?

នាក់ ៖ ដឹងតំបន់ប៉ុន្មានទេ ។

ធានី៖ តំបន់ប៉ុន្មានកាលហ្នឹង ។

នាក់ ៖ មិនដឹងតំបន់ប៉ុន្មានទេ ខ្ញុំវា ។

ធានី ៖ តំបន់១ តំបន់២ តំបន់៣?

នាក់ ៖ អាហ្នឹងបែបមកខាងកោះក្រឡ ខាងចេះជួល់មិនដឹងតំបន់ប៉ុន្មានទេ ។ បើទៅនោះតំបន់៣ ចុះមកខាងក្រោមជួល់ដឹងតំបន់៣ ដល់មកខាងលើ ខ្ញុំមិន ។

ធានី ៖ ទៅកោះក្រឡតំបន់៣ ឬក៏តំបន់?

នាក់ ៖ មិនដឹងតំបន់ប៉ុន្មានទេ ខ្ញុំមិនសួរដឹងដែរ ។

ធានី ៖ ចុះលោកតានៅតំបន់ប៉ុន្មាន?

នាក់ ៖ ខ្ញុំនៅព្រៃខ្ពួតនៅចាមរអាលមិនដឹងតំបន់ប៉ុន្មានទេ ខ្ញុំអត់ដឹងដែរ ។

ធានី ៖ អត់ដឹង ប៉ុន្តែយោធាៗតំបន់?

នាក់ ៖ បាទៗ ។

ធានី ៖ ប៉ុន្តែយោធាតំបន់ៗហ្នឹងប៉ុន្មាននាក់ ដែលគេយកចាប់មនុស្សយកទៅសម្លាប់?

នាក់ ៖ ទេ! គ្នាគេច្រើនណាស់រាប់មិន ។

ធានី ៖ ប៉ុន្តែលោកតាសួរអ្នកណា សួរទាហានយោធាហ្នឹង?

នាក់ ៖ ស្ទួរដែលទាហាន ស្ទួរយោធាហ្នឹង ថាដឹកទៅណារើសសក្ដិ១ សក្ដិ២ ហើយគេយកបែកថាអ្នកណាមានបណ្ដាសក្ដិប្រមូលទាំងអស់យកទៅទទួលសម្ដេចឪ ។ មិនសម្ដេចឪ មិនកោះក្រឡរ៉ៃចោលអស់រលីង ។ ហើយបានខ្ញុំដឹង ដែលស្រុកខ្ញុំដែលរៀនសាលាបាលីជាមួយគ្នាហ្នឹងខ្ញុំរួចខ្លួន ខ្ញុំអត់បានស្លាប់ហ្នឹងគេទេ ។ ហើយពួក៣-៤-១០នាក់ដែលនៅរៀនជាមួយគ្នាជាប់ សាលារង រៀនបំពេញវិជ្ជាបានធ្វើគ្រូទាំងអស់ ។ អាណាខ្លះពាក់សក្ដិ២កន្ទះពាក់សក្ដិ១ ហើយអាសាដង់អីហ្នឹង គេយកមករ៉ៃចោលជ្រើសឈ្មោះយកមករ៉ៃចោលអស់រលីង ។ ហើយខ្ញុំអត់មានទាក់ទងអីហ្នឹងគេទេ ។

ធានី ៖ លោកតាចាំឈ្មោះពួកម៉ាក់លោកតាដែលរៀនជាមួយគ្នាហ្នឹងទេ ប៉ុន្មាននាក់ដែលយកទៅរ៉ៃចោលហ្នឹង?

នាក់ ៖ ចាំ ។

ធានី ៖ ឈ្មោះអីខ្លះ?

នាក់ ៖ ឈ្មោះ យឹនមួយ ផានមួយ ជិបមួយ អាហ្នឹងរៀនសាលាបាលីជាមួយគ្នា ។

ធានី ៖ ៣នាក់ហ្នឹង?

នាក់ ៖ បាទ! ៣-៤នាក់ហ្នឹង ប៉ុន្មានគ្នាច្រើនណាស់ ប៉ុននៅចាំតែប៉ុនហ្នឹងគ្នា ព្រោះអីយើងនៅជាមួយគ្នា ។

ធានី ៖ ហើយពួកគាត់ហ្នឹងអ្នកនៅស្រុកជាមួយលោកតាដែរ?

នាក់ ៖ នៅស្រុកគ្នាហ្នឹង ប៉ុនតែគេ ។

ធានី ៖ បានធ្វើគ្រូបង្រៀន ធ្វើអី?

នាក់ ៖ ធ្វើគ្រូបង្រៀន កាលហ្នឹងវាគ្រូជំនាន់នោះថ្ងៃ រៀនបានសាលារងមួយចូលរៀនបំពេញវិជ្ជាបានសញ្ញាប័ត្រ ។

ធានី ៖ ទៅបានហើយ?

នាក់ ៖ ជាប់ទៅគ្រូបានរឹប គេចាប់យកក្វាម ។ ហើយតែបានគ្រូហើយ គេទិញយើងណាស់មានតម្លៃណាស់កាលហ្នឹង ។ គេទិញយើង គេមានឲ្យម៉ូតូ គេមានឲ្យអី ទិញយើងហើយគេយកទៅការកូនគេឲ្យ អាហ្នឹងមានតម្លៃខ្លាំងណាស់ ។ ហើយខ្ញុំ ថាខ្ញុំអត់ចង់បាន ខ្ញុំមិនធ្វើ ។

ធានី ៖ ម៉េចទៀតលោកតា ម៉េចទៀត ដល់ពេលជីងរឿងហ្នឹង?

នាក់ ៖ អាហ្នឹងឡាយៗមកដល់ពេលហ្នឹង មកដល់អាសម័យសម្លាប់ខ្លាំងហ្នឹង អាហ្នឹងសម្លាប់ខ្លាំងហ្នឹងយើងក្នុងម៉ាគ្រួសារគេឲ្យជីកអណ្ដូងមួយ ជម្រៅ៥ម៉ែត្រ ។

ហើយជីកអណ្តូងហ្នឹងខ្ញុំសួរថា “ជីក ធ្វើអី” ថា “ជីកទុកដាក់ទឹកផឹក” អានេះជិតដល់កំណត់គេវ៉ៃដាក់អណ្តូង ។ ហើយខ្ញុំក៏បះបោរ ទាំងអស់គ្នារត់ៗទៅ ។

ធានី : លោកតារត់?

នាក់ : បាទ! នាំគ្នារត់មកជាង៥០០រទេះមកនៅស្រុកមោងនេះ ។ ហើយក៏យួនវាទទួលស្គាល់ទៅខ្ញុំរួចខ្លួន ។ ដល់យួនទទួលស្គាល់ខ្ញុំរួចខ្លួនចឹង ក៏ខ្ញុំរែកកូនរែកចៅទៅនៅព្រំដែនថៃទៅ នៅខាងជំរំចាស់ ។

ធានី : នៅណាវិញ តាមផ្លូវណាបើពីមោងទៅ?

នាក់ : ទេ! កាលហ្នឹងគេបញ្ជូនមកមោង ខ្ញុំមកនៅអន្លង់វិលបាត់ដំបងនេះ ហើយចេញមកស្វាយចិន ទៅទឹកថ្លាចឹង រែកកូនរែកចៅចូលដីថៃទៅនៅជំរំចាស់ ។ ដល់បារាំងគាំទ្រ វាបើអង្គរ បើកមុង បើកភ្នួយ បើកអីសព្វបែបយ៉ាងឲ្យស៊ីចុកទាំងអស់ វាមិនឲ្យអត់ទេ ។

ធានី : ហើយម៉េចទៀតតា?

នាក់ : ដល់នៅជំរំចាស់ហ្នឹងបាន ប្រហែលជារយៈកន្លះឆ្នាំ បានពួកប៉ុវ៉ាមកវ៉ៃគ្នា រត់មកនៅជំរំចំការគរ ។

ធានី : លោកតារត់ទៀត?

នាក់ : បាទ! រត់មកនៅជំរំចំការគរៗនៅបានយូរៗចឹងទៅ ក៏គេពួកហ្នឹងគេចេះវ៉ៃគ្នាខ្មែរក្រហម ហើយនឹងប៉ុវ៉ា ។

ធានី : ខ្មែរក្រហមហើយនឹងប៉ុវ៉ាវ៉ៃគ្នាទៅវិញ?

នាក់ : វ៉ៃ ខ្មែរក្រហមវ៉ៃប៉ុវ៉ាៗវ៉ៃខ្មែរក្រហម ។ ប៉ុវ៉ានៅជំរំថ្មី ខ្មែរក្រហមនៅចំការគរ ហើយវ៉ៃគ្នាចឹងទៅ ។ ដល់នេះខ្ញុំរត់ចូលដីថៃទៅ ។

ធានី : រត់ទៅដីថៃខាងណា?

នាក់ : នៅខាងនងសាមីត ។

ធានី : ជំរំនងសាមីតចឹង?

នាក់ : ហ្នឹងហើយ ជំរំនងសាមីត នងចាន់នោះ ។

ធានី : នងចាន់ យ៉ាងម៉េចទៀត លោកតា?

នាក់ : ដល់នៅក្នុងជំរំហ្នឹងបានយូរៗ បាននៅក្នុងជំរំហ្នឹងហើយក៏ខ្ញុំទៅនៅយួនវ៉ៃៗជំរំថ្មីហ្នឹង ជំរំចាស់ហ្នឹង ខ្ញុំរត់ទៅនៅជំរំតាង៉ុកនោះ នៅជំរំតាង៉ុក ។ ដល់នៅជំរំតាង៉ុកហើយចឹង បានកន្លែងហ្នឹងគេបង្កើតខាងតាខៀវ សំផនហ្នឹងបង្កើត នៅ៨៥ ។

ធានី ៖ ទៅ៨៥?

នាក់ ៖ ហ្នឹងហើយ បានដឹកកូនដឹកប្រពន្ធទៅនៅ៨៥នោះ ហ្នឹងទៅនៅហ្នឹងវាឆ្ងាយពីនេះហើយទៅនៅក្នុងដីថៃជ្រៅខាងលោកតាខៀវ សំផនហ្នឹង ។

ធានី ៖ ម៉េចទៀតតា?

នាក់ ៖ ហើយដល់នៅហ្នឹងបានយូរៗទៅគេថាឥឡូវ ប្រជាជនខ្មែរត្រូវចេញពីដីថៃឲ្យអស់ ។ ក៏ឡានហ្នឹងដឹកមកនៅជប់គគីរ ។ ដឹកមកនៅជប់គគីរ បានប៉ុន្មានខែទេ ហើយថាហ៎!ឥឡូវហ្នឹងចុះពីជប់គគីរ ចៃឆ្កែមកនៅមេបុណ្យនេះ ។ មកនៅមេបុណ្យក៏នាំគ្នាមកនៅ មិនទាន់បានធ្វើស្រែស្រូវទើបទុំមិនទាន់បានច្រូតផង ប៉ាវ៉ាខ្មែរក្រហមវ៉ៃគ្នាទៀត ។ ហើយខ្ញុំមកសុំដីជ្រកនៅចៃឆ្កែនៅថ្មដែកកេះនេះពីឆ្នាំ៩៨ មកនៅហ្នឹងធ្វើកន្ទែងធ្វើអីហើយ ប៉ុនមិនទាន់មកទេ នៅបន្ទាយឆ្មារសិន ។ ដល់គេវ៉ៃដុតខ្ទេចខ្ទីអស់ចឹង ជង្រុកស្រូវអីអស់ បានគេឈប់វ៉ៃ ខ្ញុំដឹកកូនដឹកស្រូវអង្ករមកនៅនឹងថ្មដែកកេះរហូតមកទល់សព្វថ្ងៃ ។

ធានី ៖ មើលទៅកំសត់ដែរលោកតា ។ ចឹងលោកតាចង់បកក្រោយតិច អឺ!មិញលោកតាថានៅឆ្នាំ៧៥ គេឲ្យលោកតាក្តាប់ លោកតាធ្វើនៅចាមរអាលនោះ?

នាក់ ៖ បាទ!

ធានី ៖ ហើយដល់ពេលហើយលោកតាថាមានពួកគាត់អត់បាយ ម៉េចបានអត់បាយ អ្នក១៧មេសាអស់ហ្នឹង?

នាក់ ៖ គេបង្អត់ ។

ធានី ៖ គេបង្អត់?

នាក់ ៖ ខាងថ្នាក់លើគេបង្អត់ ។

ធានី ៖ អ្នកណាគេមកប្រាប់ចឹង?

នាក់ ៖ ទេ! គេៗមិនឲ្យ គេមិនប្រាប់ថាអញបង្អត់ឲ្យបាយគេមិនប្រាប់ថាចឹង ដល់ខ្ញុំនៅចាមរអាលខ្ញុំ មកព្រៃស្វាយសួរសេដ្ឋកិច្ច "ចុះម៉េចបានបង្អត់បាយចឹង" "ទៅក័យអីអា!ឲ្យរស់តែឯងទៅ ឯរាប់ៗទៅ" ។

ធានី ៖ កាលហ្នឹងលោកតាធ្វើមេភូមិ?

នាក់ ៖ ខ្ញុំប្រធានការដ្ឋាន ។

ធានី ៖ ប្រធានការដ្ឋានអាចថាស្មើមេភូមិចាមរអាល ប្រធានការដ្ឋានផ្សេង មេភូមិផ្សេង តែមួយទេ?

នាក់ ៖ បាទ! ទេ!អាហ្នឹងគ្មានមេភូមិហ៎ ។

ធានី ៖ អូ! អាហ្នឹងហៅប្រធានការដ្ឋានចាមរអាលវិញ?

នាក់ ៖ ហ្នឹងហើយ ប្រធានការដ្ឋាន ម៉ាការដ្ឋានមានប៉ុន្មានរយ ថាមានម៉ា១០០គ្រួសារ មានប្រជាជន៤០០-៥០០មានគ្នាតែ២នាក់ទេ ។

ធានី ៖ អូ! មានណាគេខ្លះទៅ?

នាក់ ៖ កាលហ្នឹងខ្ញុំនៅជាមួយតាស្រស់ ។

ធានី ៖ លោកតា?

នាក់ ៖ នៅជាមួយតាស្រស់ ។

ធានី ៖ តាស្រស់ ។ ចឹងលោកតាៗ និងលោកតាស្រស់ មួយណាប្រធាន លោកតាប្រធាន ឬតាស្រស់ប្រធាន?

នាក់ ៖ ទេ! អត់មានអ្នកណាប្រធានទេ ស្មើ ។

ធានី ៖ ស្មើគ្នា?

នាក់ ៖ ស្មើគ្នា ។

ធានី ៖ ប្រធានការដ្ឋានហ្នឹង ប្រធានការដ្ឋានចាមរអាលចឹង?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ហើយការដ្ឋានហ្នឹងគេធ្វើអីគេ?

នាក់ ៖ អាហ្នឹងគេសម្រាប់ដាំបាយ ដាំទឹកចែកពួក១៧ស៊ី ។

ធានី ៖ ចឹងអ្នកដែលមកនៅហ្នឹង សុទ្ធតែពួក១៧ទាំងអស់?

នាក់ ៖ សុទ្ធ១៧ទាំងអស់ ។

ធានី ៖ ប៉ុន្មានគ្រួសារទៅ?

នាក់ ៖ ទេ! ច្រើនណាស់រាប់មិនឈ្នះទេ ។

ធានី ៖ លោកតារកនឹកមើល?

នាក់ ៖ ច្រើន ។

ធានី ៖ ប៉ុន្មានគ្រួសារ ១០០ ២០០?

នាក់ ៖ អូ! ច្រើន ។

ធានី ៖ ១០០០?

នាក់ ៖ ច្រើន គ្រាន់តែខ្ញុំ ម៉ាការដ្ឋានខ្ញុំ៥០០គ្រួសារ ។

ធានី ៖ ចឹងគាស្រស់៥០០គ្រួសារទៀត?

នាក់ ៖ ទេ! ២នាក់គាស្រស់ហ្នឹងណា៎ ។

ធានី ៖ ៥០០គ្រួសារ ចឹងនៅការដ្ឋានហ្នឹងរបស់លោកតាហ្នឹងមានចំនួន៥០០គ្រួសារ សុទ្ធតែអ្នកប្រជាជនថ្មីទាំងអស់?

នាក់ ៖ សុទ្ធប្រជាជនថ្មីទាំងអស់ ។

ធានី ៖ ហើយពួកគាត់ទៅនៅហ្នឹង លោកតាបានទៅសួរអ្នកសេដ្ឋកិច្ចហ្នឹង អ្នកណាគេ ឈ្មោះអីគេ?

នាក់ ៖ សេដ្ឋកិច្ច មើលឈប់ ខ្ញុំនឹកមើលសិន ភ្លេចបាត់អស់ហើយចៅអើយ ។ ភ្លេចៗបាត់អស់ហើយ ភ្លេចមែនភ្លេចទេ មនុស្សស្គាល់ទាំងអស់ ប៉ុនភ្លេចឈ្មោះ ។

ធានី ៖ អូ! ភ្លេចឈ្មោះ?

នាក់ ៖ បាទ! ។

ធានី ៖ តែអ្នកសេដ្ឋកិច្ចហ្នឹង គាត់តែម្នាក់ទេ នៅព្រៃស្វាយហ្នឹង?

នាក់ ៖ ទេ! សេដ្ឋកិច្ចគេមាន៥នាក់ ។

ធានី ៖ អូ!សេដ្ឋកិច្ចមាន៥នាក់?

នាក់ ៖ បាទ!

ធានី ៖ អ្នកណាប្រធានសេដ្ឋកិច្ច?

នាក់ ៖ ប្រធានសេដ្ឋកិច្ច អឺ! ។

ធានី ៖ ចុះលោកតាសួរអ្នកណាគេ គេសួរថាហេតុអីបានអត់បាយប្រជាជនអីចឹង?

នាក់ ៖ សួរដែលសេដ្ឋកិច្ចឈ្មោះស៊ឹម ឥឡូវគេទៅនៅសហរដ្ឋបាត់ហើយ ។

ធានី ៖ ស៊ឹមហ្នឹង លោកតាបានសួរស៊ឹមហ្នឹងម៉េចបានអត់បាយអីចឹង ហើយស៊ឹមហ្នឹងមិនមែនប្រធានសេដ្ឋកិច្ចទេ ប៉ុន្តែអ្នកធ្វើសេដ្ឋកិច្ចនៅក្នុងហ្នឹងដែរ?

នាក់ ៖ ហ្នឹងៗនៅនឹងដែរ ហើយតាគឹម ។

ធានី ៖ តាគឹមប្រធាន?

នាក់ ៖ អត់ទេ គេសម្រាប់ចែកចាយ ។

ធានី ៖ តាគឹមចែកចាយ?

នាក់ ៖ បាទ! ដល់ខ្ញុំសួរទៅ ហ៎!អញមិនដឹងទេឲ្យរស់តែយើងទៅ អញគ្មានអីចែកទេ ដល់នេះកុហកទៅថាឥឡូវឡានខូចនៅនេះនោះ ដើរនយោបាយកុហកទៅ កុំឲ្យប្រជាជនធ្វើបាបយើងកុហក

ទៅថាឡានខូចនេះខូចនោះចឹងទៅ ដើរនយោបាយកុហកទៅណា កុំឲ្យប្រជាជនធ្វើបាបយើង កុហក ទៅថាឡានខូចនេះខូចនោះ នៅនេះនៅនោះចឹងទេ ។

ធានី : កុហកប៉ុន្មានដងទៅលោកតា បើគិត?

នាក់ : ទេ! កុហកនោះវាញឹកញាប់ដែរ មើលអត់បាយ៣-៤-៥ថ្ងៃសួរថា "ម៉េច មិនឃើញយកអង្ករមក" គេប្រាប់ថា "អូ!ឡានខូចទៅណាៗនោះទៅមកមិនរួចទេ" ។

ធានី : ដល់ចឹងប្រជាជននៅហ្នឹងក្រៅពីយកអង្ករមកពីខាងលើមក អត់មានអីហូបទៀតទេ?

នាក់ : អត់ទេ គ្មានទេ ។

ធានី : អត់មានធ្វើស្រែធ្វើអីបាន?

នាក់ : ធ្វើអីគេនៅក្តោបក្តាប់ជាប់នៅដីបងវៃរាល់ថ្ងៃ ។

ធានី : អូ! វៃរាល់ថ្ងៃ?

នាក់ : អឺ! អាណាលួច ឈ្លបគេហ្នឹងវៃផុសៗហ្នឹង ។

ធានី : ខាងណាឈ្លបគេ មិនមែនលោកតាក្តាប់ទេ?

នាក់ : អត់ទេ ឈ្លបគេផ្សេង ។

ធានី : ឈ្លបខាងណាមកវិញ?

នាក់ : ឈ្លបខាង ។

ធានី : ខាងឃុំ ហើយខាងស្រុក?

នាក់ : ខាងឃុំ ។

ធានី : ឃុំអីគេកាលហ្នឹង ឃុំ?

នាក់ : ឃុំ ហ៉ឺ!ចាមរអាលបែបឃុំ មិនដឹងឃុំអីគេទេឃុំ ភ្លេចឃុំអស់ហើយ ។

ធានី : ឃុំព្រៃស្វាយ?

នាក់ : មិនមែន ដូចឃុំគួយជីកដីចេះមិនដឹង ឃុំគួយជីកដី ខ្ញុំមិនសូវចាំដែរវា ។

ធានី : ចឹងខាងឃុំគេអ្នកបញ្ជាឲ្យឈ្លបហ្នឹងមកវៃ?

នាក់ : គេចាត់ចែងឲ្យឈ្លបមកមើលការខុសត្រូវ ។

ធានី : ប៉ុន្មាននាក់ទៅលោកតា ដែលឈ្លបមើលការណ៍?

នាក់ : ឈ្លបជួនណា៤-៥-៦នាក់នេះ គេដើរធ្វើការទាំងយប់ទាំងថ្ងៃទៅ ។ ហើយអាណាលួចឆក់អី អ្នកហ្នឹងត្រូវដីបងរបស់គេ ។

ធានី : ចឹងហ៉ឺ! មានស្លាប់ច្រើនទេ អ្នកភូមិយើងកាលនៅចាមរអាលហ្នឹង?

នាក់ ៖ ទេ! ស្លាប់នោះវាលែងគិតហើយ តាំងគេទាំងឯង ទាំងថ្មីទាំងចាស់ងាប់ដូចគ្នា ។

ធានី ៖ ប៉ុន្មាននាក់ម៉ាថ្ងៃអាចស្មានបានទេ?

នាក់ ៖ ទេ! អានេះកាលខ្ញុំនៅហ្នឹង យកពីពេទ្យចាមរអាលម៉ាយប់ម៉ាថ្ងៃៗ ទៅឲ្យជីករណ្ដៅឲ្យវែង ឲ្យជ្រៅ ។ ហើយខ្មោចងាប់ហ្នឹងម៉ាយប់ម៉ាថ្ងៃហ្នឹង ជួនណាមាន១៥នាក់ មាន២០នាក់ យកចាក់ចោលក្នុងរណ្ដៅហ្នឹងលុបទៅ ។ ងាប់នោះងាប់ៗ ដល់ទាំងគេទាំងយើង ចុះអត់បាយ មិនថាតែ១៧ អា១៨ក៏ងាប់ដែរ ។

ធានី ៖ តែស្លាប់ដោយសារអត់បាយ មិនមែនវ៉ៃចោល?

នាក់ ៖ ហ្នឹងស្លាប់ៗដោយសារអត់បាយច្រើន ។

ធានី ៖ គេបន្តត់មែន លោកតា?

នាក់ ៖ ហ្នឹងហើយ ដល់ពេលអាវ៉ៃចោលអាយួនចូលនេះ អាហ្នឹងនៅសហករណ៍ធ្នួយ អត់សល់ម្នាក់ទេ ស្អុយពេញព្រៃ ។

ធានី ៖ សហករណ៍អីគេ?

នាក់ ៖ សហករណ៍ធ្នួយ ។

ធានី ៖ សហករណ៍ឃ្នួញ?

នាក់ ៖ ធ្នួយ ។

ធានី ៖ ធ្នួយៗនៅណាវិញ សហករណ៍ធ្នួយហ្នឹង?

នាក់ ៖ ធ្នួយហ្នឹងនៅបៀតព្រែកជីក អាហ្នឹងខ្ញុំនៅខាងបៀតហ្នឹងហើយ ។

ធានី ៖ ធ្នួយ?

នាក់ ៖ ធ្នួយ ខាងស្រែប្រាំងហ្នឹង ។

ធានី ៖ ធ្នួយបៀត?

នាក់ ៖ បៀតស្រែប្រាំង មើលឈប់ឈ្មោះ អឺ!ស្អីគេ ។

ធានី ៖ ហើយភូមិអីគេ ធ្នួយហ្នឹង?

នាក់ ៖ ធ្នួយហ្នឹង ភូមិធ្នួយហ្នឹង ប៉ុនគេធ្វើសហ ។

ធានី ៖ ឃុំអីគេ?

នាក់ ៖ មិនដឹងឃុំអីគេទេ ឆ្ងាយពីគ្នាណាស់ ។

ធានី ៖ តែនៅក្នុងស្រុកមោងយើងដែរ?

នាក់ ៖ បាទ! ប៉ុនខ្ញុំនៅខាងបឹងឆ្ការ ហើយនៅខាងបឹងឆ្ការហ្នឹង សហករណ៍ហ្នឹងវៃចោលរលីង ហើយផ្លូវខ្ញុំចេញចូលហើយស្អុយពេញព្រៃទាំងអស់ ។

ធានី ៖ បឹងឆ្ការហ្នឹង លោកតានៅបឹងឆ្ការ?

នាក់ ៖ បាទ!

ធានី ៖ ហើយលោកតាជិះទៅតាមផ្លូវហ្នឹងបានដឹងថា?

នាក់ ៖ អត់ទេ ជិះកាត់ផ្លូវចេះ ។

ធានី ៖ កាត់ផ្លូវធ្លុយហ្នឹង?

នាក់ ៖ មិនៗមែនកាត់ផ្លូវធ្លុយទេ កាត់ផ្លូវមកកន្លែងគេធ្វើស្រែប្រាំង ។

ធានី ៖ ស្រែប្រាំង?

នាក់ ៖ អឺ! ហើយព្រៃគេយកទៅវៃហើយ យកទៅចោលហ្នឹង អត់មានកប់មានអីមានអីចោលនៅកណ្តាលហ្នឹង ។

ធានី ៖ ចឹងស្អាប់ពេញព្រៃ?

នាក់ ៖ ស្អាប់ពេញព្រៃ ហើយថ្ងៃមួយនោះខ្ញុំមកពីបឹងឆ្ការអាហ្នឹងមនុស្សខ្ញុំស្គាល់ហើយ ស្រីៗ២នាក់វៃពីព្រលប់ទល់ភ្លឺ ។

ធានី ៖ ស្រីហ្នឹងអ្នកវៃ?

នាក់ ៖ ស្រីអ្នកវៃ ។

ធានី ៖ ឈ្មោះអីគេលោកតា?

នាក់ ៖ ឈ្មោះ ធីមមួយ ជុំមួយ ។

ធានី ៖ ២នាក់ហ្នឹងស្រីទាំង២?

នាក់ ៖ ស្រីទាំង២ ។

ធានី ៖ ស្រីឈ្លប?

នាក់ ៖ អត់ទេ ។

ធានី ៖ ជាអីគេ គេអ្នកវៃសម្លាប់មនុស្ស?

នាក់ ៖ អត់ទេ គេបញ្ជាឲ្យវៃតែម៉ង ។

ធានី ៖ វៃមនុស្សនៅណា?

នាក់ ៖ នៅព្រៃខ្ទូត ។

ធានី ៖ ព្រៃខ្ទូតទាំងអស់ហ្នឹង ដែលថា?

នាក់ ៖ ទេ! អាហ្នឹងម៉ាវគ្គទៀត ។ ដល់ខ្ញុំបរទេះមក ចុះឃើញដីប៉ុន្មានហិចតាគួរឲ្យពេញទាំងអស់សួរ "ស្អីហ្នឹងអ៊ី" ព្រិលៗដល់ស្អី ខ្មោច ។

ធានី ៖ លោកតាសួរធីម ហើយដុំហ្នឹង?

នាក់ ៖ អត់ទេ មិនទាន់សួរគេ ប៉ុនឃើញៗ ដល់ទៅដល់ផ្ទះឪពុកមីដុំហ្នឹងឈ្មោះ តាមិនៗហ្នឹង ខ្ញុំសួរ "ចុះដីតាជ៉ោល ហេតុអីបានមនុស្សងាប់ច្រើនម៉េច" "អឺ!តាដុំ ហើយតាធីម ដាក់ទល់ក្បីអស់ប៉ុន្មានរយនាក់នោះ" ។

ធានី ៖ ប៉ុន្មានរយទៅតាដឹងទេ?

នាក់ ៖ ទេ! ច្រើន ដីប៉ុន្មានហិចតាឃើញដល់ ហ៉ា!បែបច្រើនៗជាង១០០ ។

ធានី ៖ ដីប៉ុន្មានហិចតាកាលហ្នឹង?

នាក់ ៖ ដីប្រហែលដីស្រែប៉ុន្មានហិចតាហ្នឹង ឃើញអាដីផ្លូវបរទេះហ្នឹង ឃើញនៅពេញហ្នឹងទាំងអស់រណ្ដៅករណែល ។

ធានី ៖ អ្នកប្រជាជនស្លាប់ហ្នឹង ប្រជាជនថ្មី ឬចាស់?

នាក់ ៖ ប្រជាជនថ្មី ។

ធានី ៖ គេវៃសម្លាប់ទាំងអស់?

នាក់ ៖ គេវៃសម្លាប់ទាំងអស់ ។

ធានី ៖ ប្រហែលជា៣ហិចតា ២ហិចតា ម៉ាហិចតា?

នាក់ ៖ ស្រែហ្នឹងប្រហែលជា១២ហិចតា ។

ធានី ៖ ២ហិចតា ពេញៗផ្លូវ?

នាក់ ៖ អឺ! ឃើញនៅរណ្ដៅករណែលពេញដីហ្នឹង ។

ធានី ៖ ពេញដី?

នាក់ ៖ ហើយដល់ខ្ញុំទៅផ្ទះ ខ្ញុំសួរ ។

ធានី ៖ សួរតាមិន?

នាក់ ៖ ហ្នឹងហើយសួរគាត់ សួរឪមីដុំ ហើយគាត់ថា "ដុំ ហើយធីម លេងពីល្ងាចមិញតាំងពីព្រលប់ទល់ភ្លឺ អស់មិនដឹងប៉ុន្មានរយ" ។

ធានី ៖ ហើយប្រជាជនហ្នឹងមកពីណាវិញ តា?

នាក់ ៖ ទេ! មិនដឹង សុទ្ធតែប្រជាជនថ្មី ។

ធានី ៖ តែចល័តនៅព្រៃខ្លួតហ្នឹង?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ហើយម៉េចទៀតតាតា ដល់ពេលលោកតាបរទេះសេះ ម៉េចបានលោកតាបរទេះសេះទៅនៅកន្លែងបឹងឆ្ការ?

នាក់ ៖ ខ្ញុំទៅនៅបឹងឆ្ការ ប៉ុនកន្លែងទីតាំងនៅចាមរអាលនេះ ។

ធានី ៖ ចាំ! ទៅបឹងឆ្កាធ្វើអី?

នាក់ ៖ ទៅបឹងឆ្ការទៅធ្វើចំការ ។

ធានី ៖ ធ្វើចំការ?

នាក់ ៖ បាទ!

ធានី ៖ លោកតាធ្វើចំការម្នាក់ឯង?

នាក់ ៖ ទេ! គ្នាច្រើន ។

ធានី ៖ ជាមួយកងចល័តរបស់តា?

នាក់ ៖ ជាមួយកងខ្ញុំហ្នឹង វាម៉ាកងតូច ។

ធានី ៖ ធ្វើស្រែ អាហ្នឹងគេហៅស្រែ តំបន់?

នាក់ ៖ ធ្វើៗចំការ ។

ធានី ៖ ធ្វើចំការដាំអីគេ?

នាក់ ៖ ដាំដំឡូង

ធានី ៖ អូ! ចំការដាំដំឡូង?

នាក់ ៖ ធ្វើឲ្យគណៈសហករណ៍គេ គេចាត់ចែងឲ្យទៅធ្វើ ។

ធានី ៖ ឲ្យសហករណ៍ៗអីគេ?

នាក់ ៖ សហករណ៍នៅចាមរអាលហ្នឹង ។

ធានី ៖ អូ!សហករណ៍ចាមរអាល ។ ក្រែងលោកតាខាងការដ្ឋាន?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ចឹងសហករណ៍ធំដាង?

នាក់ ៖ ហ៊ាំ! ធំដាងគេប្រធានៗសហករណ៍ ឈ្មោះណេងហ្នឹង ។

ធានី ៖ អូ! ប្រធានសហករណ៍ឈ្មោះណេងហ្នឹង?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ណោងប្រធានសហករណ៍ ។ ម៉េចទៀតលោកតា ដល់ពេលលោកតាជិះកាត់ហើយ ឃើញចឹង ហើយម៉េចទៀត?

នាក់ ៖ អាហ្នឹងខ្ញុំសួរគេ គេប្រាប់ចឹងចប់ទៅ ។

ធានី ៖ ចប់ហើយទៅមុខទៀតទៅ?

នាក់ ៖ ខ្ញុំចូលមកកន្លែងខ្ញុំមក ចឹងអស់ហើយ ។

ធានី ៖ អស់ប៉ុនហ្នឹងហើយ?

នាក់ ៖ (សើច) ។

ធានី ៖ ចឹងពេលលោកតា មិញលោកតាថាលោកតានៅធ្វើការដ្ឋានជាមួយអ្នក១៧មេសា អត់ហូប អត់អីហើយ ចឹងប្រជាជនលោកតានៅក្នុងការដ្ឋានហ្នឹងមានប៉ុន្មានអ្នក១៧ដែលនៅរស់?

នាក់ ៖ ទេ!

ធានី ៖ ក្រោយមកទៀត លោកតាដូរទៅធ្វើការកន្លែងផ្សេងអត់?

នាក់ ៖ ខ្ញុំៗដល់នេះ ខ្ញុំប្រគល់ឲ្យគេក្តោបក្តាប់ទៅ ខ្ញុំគេឲ្យទៅធ្វើចំការ ។

ធានី ៖ ធ្វើចំការដែលលោកតាកាត់ព្រៃឆ្ការហ្នឹង?

នាក់ ៖ ហ្នឹងហើយ គេលែងឲ្យធ្វើប្រធានការដ្ឋានហើយ ឲ្យៗ ។

ធានី ៖ ឆ្នាំប៉ុន្មាន ដែលគេដូរលោកតាទៅធ្វើចំការដំឡូងហ្នឹង?

នាក់ ៖ ឆ្នាំ៧៥ហ្នឹង ។

ធានី ៖ អឺ! ព្រោះលោកតា៧៥ លោកនៅធ្វើជាប្រធានទទួលខាងប្រជាជន ប្រធានការដ្ឋាន?

នាក់ ៖ ហ្នឹងហើយ ដល់នេះគេដកខ្ញុំចេញ ។

ធានី ៖ ហើយប៉ុន្មានខែ ធ្វើបានប៉ុន្មានខែ?

នាក់ ៖ ហ៎! ធ្វើបាន២-៣ខែ ។

ធានី ៖ បាន ២-៣ខែ?

នាក់ ៖ អឺ! ហើយគេដកខ្ញុំទៅ ឲ្យទៅធ្វើចំការម្តង ។

ធានី ៖ រយៈពេល២-៣ខែ?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ក្រោយពេលទទួលប្រជាជនហើយ?

នាក់ ៖ គេដកឲ្យទៅធ្វើ ។

ធានី ៖ ម៉េចបានគេដកលោកតាចេញ?

នាក់ ៖ ខ្ញុំ គេដកឲ្យទៅធ្វើចំការ ព្រោះអីខ្ញុំខានដាំដុះអី ខ្ញុំប៉ិនប្រសព្វ ។

ធានី ៖ ដំឡូងនៅណាវិញ ធ្វើចំការដំឡូង?

នាក់ ៖ នៅបឹងឆ្ការ ។

ធានី ៖ នៅបឹងឆ្ការៗ?

នាក់ ៖ បាទ!

ធានី ៖ ភូមិឃុំអីដែរ លោកតាដឹងទេ?

នាក់ ៖ ទេ! អាហ្នឹង ឃុំព្រៃត្រឡាច ។

ធានី ៖ ឃុំព្រៃត្រឡាច?

នាក់ ៖ បាទ! ស្រុកមោង បាត់ដំបង ។

ធានី ៖ ស្រុកមោង បាត់ដំបង ។ ចឹងដកទៅធ្វើចំការដំឡូង លោកតាគ្រប់គ្រងមនុស្សប៉ុន្មាននាក់ទៅ?

នាក់ ៖ ម៉ាកងតូច ។

ធានី ៖ ប៉ុន្មាននាក់ម៉ាកងតូច?

នាក់ ៖ ៣០នង្គ័ល ។

ធានី ៖ ៣០នង្គ័ល?

នាក់ ៖ បាទ!

ធានី ៖ នង្គ័លហ្នឹងសុទ្ធតែចាស់ ឬក៏?

នាក់ ៖ សុទ្ធតែអ្នកមានប្រពន្ធមាន ។

ធានី ៖ អ្នកមានគ្រួសារ?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ប្រុសៗ?

នាក់ ៖ ប្រុសៗស្រីៗទៅរញ៉េករញ៉ាក ពេញទឹកពេញដី ។

ធានី ៖ អូ! មានគ្រួសារទៀត?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ចឹងទៅទាំងប្ដីទាំងប្រពន្ធ?

នាក់ ៖ ទៅទាំងប្ដីប្រពន្ធ ជួនណាអ្នកអត់ប្រពន្ធហ្នឹងក៏គេឲ្យទៅដែរ ។

ធានី ៖ អូ! ១៩៧៩ដដែរ?

នាក់ ៖ បាទ!

ធានី ៖ ហើយទៅដល់ហ្នឹងទៅធ្វើហ្នឹងតែម៉ាមុខទេ ឈប់ធ្វើអីទៀតទេហើយ?

នាក់ ៖ អត់មានធ្វើអីទេ ធ្វើចំការ ។

ធានី ៖ ធ្វើចំការរហូត?

នាក់ ៖ បាទ! រហូតដល់យួនចូលម៉ង់ បានរត់ចេញ ។ ចឹងអស់ហើយខ្ញុំគ្មានស្អីទៀត ។

ធានី ៖ ចឹងខ្ញុំចង់សួរលោកតាតិច លោកតាមានស្គាល់ពេទ្យនៅហ្នឹង ពេទ្យនៅចាមរអាលឈ្មោះអី គេខាងពេទ្យ?

នាក់ ៖ អឺ! ភ្លេចបាត់អស់ហើយ ឈ្មោះភ្លេច ប៉ុនមនុស្សនៅស្គាល់ ។

ធានី ៖ រកនឹកមើលលោកតា?

នាក់ ៖ អត់ទេ ភ្លេចបាត់ហើយ ។

ធានី ៖ ភ្លេចបាត់ សារឿន?

នាក់ ៖ ហ៎!

ធានី ៖ ឈ្មោះ សារឿន?

នាក់ ៖ ហ៎! សារឿនមិនមែនទេ ។ នៅហ្នឹងចាមរអាលហ្នឹង ពេទ្យគេមួយហ្នឹង ប៉ុនប្រធានគេឈ្មោះប៊ិតូ ។

ធានី ៖ ប៊ិ តូច?

នាក់ ៖ តូច ។

ធានី ៖ គាត់ហ្នឹងចិត្តល្អ ចិត្តអាក្រក់?

នាក់ ៖ ទេ! ប៊ិហ្នឹង វាកណ្តាលមនុស្ស ។

ធានី ៖ កណ្តាលមនុស្ស?

នាក់ ៖ កណ្តាលចិត្តថាមិនល្អក៏មិនល្អ ថាមិនអាក្រក់ក៏មិនអាក្រក់ ។

ធានី ៖ ឈ្មោះតូចឹង?

នាក់ ៖ ឈ្មោះតូ ។

ធានី ៖ ចុះមានកូនមានអីទេ?

នាក់ ៖ កូនមាន ប្រពន្ធមាន ។

ធានី ៖ កូនប៉ុន្មានប៉ុន្មានដែលពូដឹងទេ?

នាក់ ៖ កាលខ្ញុំទៅកូនមួយ ។

ធានី ៖ ចុះមានពេទ្យណាផ្សេងទៀតទេ?

នាក់ ៖ ពេទ្យមាន ប៉ុនមិនដឹងវាក្មេចអស់ហើយ ។

ធានី ៖ ចុះលោកតាមានស្គាល់ពេទ្យស្រុកទេ?

នាក់ ៖ អូ! ពេទ្យស្រុកអត់ស្គាល់ទេ ។

ធានី ៖ អត់ស្គាល់ នៅចាមរអោលស្គាល់តែពេទ្យតូហ្នឹងទេ?

នាក់ ៖ ហ្នឹងហើយស្គាល់តែពេទ្យនៅហ្នឹងឃុំហ្នឹងទេ ពេទ្យស្រុកអត់ស្គាល់ទេ ។

ធានី ៖ ចុះលោកតាដឹង គណៈស្រុកឈ្មោះអី?

នាក់ ៖ គណៈស្រុក មិនសូវស្គាល់ហ្នឹងគេទេ គណៈស្រុកខ្ញុំភ្លេចឈ្មោះចៅ ភ្លេចឈ្មោះ ។

ធានី ៖ ភ្លេចលោកតា?

នាក់ ៖ ភ្លេច ។

ធានី ៖ អឺ!លោកតា ក្នុងនេះលោកតាថា អត់បាយៗប្រជាជនព្រោះដល់គ្រូនអឺ៨ខែនោះ ដល់ពេល លោកតានៅតែប៉ុន្មានតែ២-៣ខែទេ?

នាក់ ៖ បាទ!

ធានី ៖ នៅចាមរអោលហ្នឹង?

នាក់ ៖ ទេ! ខ្ញុំនៅធ្វើស្រែៗហ្នឹងគេមិនឲ្យធ្វើប្រធានការដ្ឋានទេ ខ្ញុំគេថាឥឡូវទៅធ្វើស្រែនៅរំលេង ខ្ញុំ ទៅ៨ខែ គិតទៅគ្រូន៨ខែ ។

ធានី ៖ លោកតាឈឺ?

នាក់ ៖ ឈឺ ។

ធានី ៖ ឆ្នាំប៉ុន្មាន ដែលលោកតាគ្រូនឈឺហ្នឹង?

នាក់ ៖ ឆ្នាំៗប៉ុន្មានទេ ក្នុងវ័យខ្មែរក្រហមហ្នឹង ដឹងឆ្នាំប៉ុន្មាន បើមិន៧៤ ៧៥ ។

ធានី ៖ ៧៤ ៧៥ ព្រោះលោកតាថាបង្អត់បាយ ហើយគ្រូនរហូត៨ខែនោះ វាចង់ម៉ាឆ្នាំហើយ?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ហើយពេលហ្នឹងលោកតាថា លោកតាទទួលប្រជាជនមកពី១៧មេសា មកពីភ្នំពេញហើយ?

នាក់ ៖ ទទួលប្រជាជនពីភ្នំពេញ៧៥ ។

ធានី ៖ ចាំ! ដល់ពេលហើយលោកតាឈឺ៨ខែណាំ?

នាក់ ៖ ខ្ញុំ មុន៧៥ខ្ញុំធ្វើស្រែ ។

ធានី ៖ ចឹងលោកតាគ្រូនឈឺហ្នឹង មុន៧៥ទេ?

នាក់ ៖ ហ្នឹងហើយ ដល់តើ ។

ធានី ៖ ចឹងលោកតាព្យាបាលនៅណា?

នាក់ ៖ ព្យាបាលនៅពេទ្យហ្នឹង ។

ធានី ៖ ពេទ្យនៅណា?

នាក់ ៖ ជាមួយអាប៉ិតូហ្នឹង ។

ធានី ៖ ពេទ្យតូ?

នាក់ ៖ គេជួសឈាម ជួសអីឲ្យ ។

ធានី ៖ ប៉ុន្តែកាលហ្នឹងមានពេទ្យហ្នឹងហើយ ពេទ្យហ្នឹងមានយូរហើយ?

នាក់ ៖ ហ្នឹងហើយមានយូរហើយ ។

ធានី ៖ ហើយលោកតាបន្ទាប់មកទៀត លោកតាថា គេស៊ើរើចាប់សោ ភីម សោអីម៉េចនោះ?

នាក់ ៖ អាហ្នឹងគេស្រាវជ្រាវរើកូនទាហានសោ ភីម ។ អាហ្នឹងគេឲ្យស្រាវជ្រាវមើលអ្នកណាទាហាន សោ ភីម អ្នកណាអីៗហ្នឹង ។

ធានី ៖ លោកតាអ្នកស្រាវជ្រាវដែរ?

នាក់ ៖ ទេ! ខ្ញុំអត់ទេ គេប្រាប់ឈ្លប គេដើរប្រាប់ឲ្យ ។

ធានី ៖ ហើយម៉េចលោកតាដឹង?

នាក់ ៖ ខ្ញុំចេះដឹងហើយ ។

ធានី ៖ ម៉េចបានគេឲ្យលោកតាដឹង លោកតាសួរអី គេអត់ថាអី?

នាក់ ៖ គេមានថាអី ចុះពួកឈ្លបពួកអីហ្នឹង ។

ធានី ៖ គេប្រាប់ថាម៉េច?

នាក់ ៖ គេថា *"មានទាហានសោ ភីម មកនៅហ្នឹងដែរអត់ទេ?"*

ធានី ៖ អូ! គេសួរចឹង គេសួរលោកតា?

នាក់ ៖ អត់ទេ ថាខ្ញុំអត់ដឹងទេ ។

ធានី ៖ ហើយម៉េចទៀតទៅ លោកតា?

នាក់ ៖ ហើយខ្ញុំឆ្លើយថាមិនដឹង គេស្រាវជ្រាវរកទៅ ឃើញគេយកវើចោលទៅ ខ្ញុំអត់ប៉ះពាល់អីនឹង គេទេ តែប៉ុន ។

ធានី ៖ ចឹងប៉ុន្មាននាក់ទៅលោកតាកាលហ្នឹង គេស្រាវជ្រាវរកឃើញប៉ុន្មាននាក់ទៅ?

នាក់ ៖ ទេ! មិនដឹងដែរ តែស្រាវជ្រាវគេអត់ប្រាប់យើងទេ តែបានយកទៅបាត់ៗ ។ ខ្ញុំរឿងចឹងៗ ប៉ុនសរសៃរសក់ខ្ញុំអត់បៀតបៀនទេ ខ្ញុំខ្លាចបាបណាស់ ។

ធានី ៖ ខ្លាចដែរ?

នាក់ ៖ បាទ! ខ្ញុំអត់មានពាក់ព័ន្ធអីហ្នឹងគេទេ គេធ្វើម៉េចធ្វើទៅ ។

ធានី ៖ ចឹងលោកតា កាលហ្នឹងគេថាឲ្យគ្រួសារមួយៗដើរដីអណ្ដូងរតាមផ្ទះនីមួយៗឲ្យបាន៥ម៉ែត្រអីអាហ្នឹង ម៉េចវិញ?

នាក់ ៖ អាហ្នឹង ។

ធានី ៖ លោកតា ជីកដែរអត់?

នាក់ ៖ ជីក ។

ធានី ៖ ជីកដែរ?

នាក់ ៖ ជីកក្បែរផ្ទះចឹង ដល់ពេលមិនទាន់បានវ៉ៃចោលផង យួនចូលខ្ញុំរត់ទៅ បរទេះរត់ដឹកកូនដឹកចៅបានរួចខ្លួន កុំអីគេវ៉ៃចោលហ្នឹងអស់ ។

ធានី ៖ បន្ទាប់មកទៀត លោកតថាទៅនៅជំរំ បន្ទាប់មកទៀតលោកតាបានរត់ទៅនៅជំរំប៉ាវ៉ាអីហ្នឹងចឹង គេវ៉ៃគ្នា ម៉េចបានគេវ៉ៃគ្នា?

នាក់ ៖ ទេ! មិនដឹង ខ្មែរក្រហម ហើយនឹងប៉ាវ៉ា គេស្អប់គ្នាម៉េចទេ ខ្ញុំមិនសូវដឹងរឿង គេកាត់ ។

ធានី ៖ ចុះលោកតា កាលពេលនៅជំរំហ្នឹង នៅជំរំចាស់កន្លះឆ្នាំ នៅធ្វើអីគេ?

នាក់ ៖ ខ្ញុំទៅភៀសខ្លួនទៅ ។

ធានី ៖ ភៀសខ្លួន ទៅស្នាក់នៅបណ្ដោះអាសន្ន?

នាក់ ៖ ទៅស្នាក់នៅបារាំងចិញ្ចឹម ។

ធានី ៖ ជំរំចំការគរក៏ចឹងដែរ?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ទៅរស់ហូបហ្នឹង អត់មានទាហានមានអីទេ?

នាក់ ៖ អត់ទេ អត់មានធ្វើអីទេ ។

ធានី ៖ ចុះបន្ទាប់មកទៀត លោកតាថានៅជំរំនងសាមី នងចាន់អីក៏ចឹងដែរ?

នាក់ ៖ អាហ្នឹងនៅជំរំចាស់ ជំរំថ្មី ចំការគរ ជំរំតាឌុំក ៨៥ អាហ្នឹងសុទ្ធតែទៅឲ្យតែរួចខ្លួន ។

ធានី ៖ ចេះរស់ចឹង?

នាក់ ៖ ឲ្យសុខ ។

ធានី ៖ ចុះជំរំតាឌុំកហ្នឹង វាមិនមែននៅខាងជំនៀរយើងនេះទេ នៅខាងនោះវិញ លោកតាទៅម៉េចទៅដល់ទៅ?

នាក់ ៖ ម៉េច មិនៗឆ្ងាយណា៎ ។

ធានី ៖ នៅណាវិញ?

នាក់ ៖ ចេញពីនងង៉ាមទៅ ទៅចូលដីក្រហម បារាំងបណ្ដើរទៅ ។

ធានី ៖ ដល់ជំរំតាង៉ុកហ្អឹង?

នាក់ ៖ ហ្អឹងហើយ ។

ធានី ៖ មិនមែននៅម៉ាឡៃទេ ជំរំតាង៉ុកហ្អឹង?

នាក់ ៖ ទេ! មិនមែនម៉ាឡៃ ។

ធានី ៖ ចុះជំរំ៨៥?

នាក់ ៖ ជំរំ៨៥ហួស ។

ធានី ៖ ហើយម៉េចបានលោកតា អាចទៅដល់ហ្អឹង?

នាក់ ៖ អានេះកន្លែងតាខៀវ សំផន ។

ធានី ៖ តាខៀវ សំផនឲ្យទៅ?

នាក់ ៖ ហ្អឹងហើយ ។

ធានី ៖ ចុះក្រែងលោកតាថាដំបូងថានៅនងចាន់ នងអី ម៉េចបានទៅដល់ជំរំតាង៉ុក ហើយទៅដល់តាខៀវ សំផន?

នាក់ ៖ ទៅដល់ជំរំតាង៉ុក អាហ្អឹងដល់គេបង្កើតជំរំហ្អឹងទៀត សុំគេទៅ ។

ធានី ៖ អូ! លោកតាសុំគេទៅ?

នាក់ ៖ បាទ!

ធានី ៖ ហើយជំរំតាង៉ុកជាកន្លែងអី ជំរំ៨៥ជាកន្លែងអី?

នាក់ ៖ ជំរំតាង៉ុក ជំរំបារាំង ។

ធានី ៖ អូ! ជំរំបារាំង?

នាក់ ៖ អឺ!

ធានី ៖ បារាំងៗស្នាក់នៅ បារាំងឲ្យ?

នាក់ ៖ បារាំងចែកចាយ បារាំងចិញ្ចឹមអ្នកភៀសខ្លួន ។

ធានី ៖ បន្ទាប់មកទៀត?

នាក់ ៖ ហើយដល់ពេលមកនៅជំរំចាស់ ជំរំថ្មី នងចាន់ ចំការគរ អានេះសុទ្ធតែបារាំងចិញ្ចឹមហើយ អានេះយើងបានម៉ារួចខ្លួន ។ ដល់ទៅ៨៥ អាហ្អឹងបារាំងអត់ចិញ្ចឹមទេ ។

ធានី ៖ ខៀវ សំផនវិញ?

នាក់ ៖ ខៀវ សំផន ចិញ្ចឹម ។

ធានី ៖ ម៉េចលោកតាដឹងថា គាត់?

នាក់ ៖ អឺ! បើគេបង្ហាញ តាខៀវ សំផនបង្ហាញ ។

ធានី ៖ តាខៀវ សំផន បង្ហាញម៉េច?

នាក់ ៖ បង្ហាញថាដំរីនេះ ដំរីតាខៀវ សំផន ។

ធានី ៖ អូ!គេប្រាប់ចឹង?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ជប់គគីរហ្នឹងនៅណាវិញ?

នាក់ ៖ ជប់គគីរនៅខាងនេះ អាហ្នឹងចេញពីដំរីអស់ហើយ មកនៅជប់គគីរហ្នឹង ។

ធានី ៖ ជប់គគីរ នៅកន្លែងណាវិញ?

នាក់ ៖ ជប់គគីរនៅក្បែរជើងភ្នំ ។

ធានី ៖ ជើងភ្នំអីគេ?

នាក់ ៖ ជើងភ្នំជប់គគីរហ្នឹង ។

ធានី ៖ ជើងភ្នំជប់គគីរនៅខេត្តឧត្តរមានជ័យហ្នឹង?

នាក់ ៖ ហ៊េ! មិន ។

ធានី ៖ នៅភ្នំដងរែកហ្នឹង ជប់គគីរហ្នឹង?

នាក់ ៖ ភ្នំដងរែក ។

ធានី ៖ នៅឧត្តរមានជ័យនៅកន្លែងច្រកគេហ្នឹងមែន គេហៅជប់គគីរហ្នឹង?

នាក់ ៖ ជប់គគីរហ្នឹង ។

ធានី ៖ ច្រកចេញចូលថៃ ឬក៏យ៉ាងម៉េច?

នាក់ ៖ ទេ! អាហ្នឹងយើងមកនៅជប់គគីរហ្នឹង អត់មានចេញចូលថៃទេ ។

ធានី ៖ ប៉ុន្តែយើងនៅលើភ្នំដងរែកហ្នឹង?

នាក់ ៖ ហ្នឹងហើយ យើងមកនៅភ្នំចេះ យើងមកនៅក្រោមចេះ ។

ធានី ៖ នៅជំនៀវភ្នំ?

នាក់ ៖ ជំនៀវភ្នំ ប៉ុនអូ!ចាញ់ដល់ហើយ ។

ធានី ៖ ចាញ់?

នាក់ ៖ ចាញ់វាអត់ទឹក ។

ធានី ៖ ចុះនៅជប់គគីរហ្នឹងមានអ្នកធំៗគេមកនៅហ្នឹង?

នាក់ ៖ ទេ! អ្នកធំៗគេអត់នៅទេ គេនៅគេសុទ្ធតែឡានទៅមកៗ គេត្រូវការអីឡានគេមកគេប្រាប់មេភូមិ មេក្រុម គេកងគេទៅ ។

ធានី ៖ ចុះលោកតាកាលហ្នឹងនៅធ្វើអី?

នាក់ ៖ ខ្ញុំអត់ធ្វើអីទេ ។

ធានី ៖ អូ! ប្រជាជនធម្មតា?

នាក់ ៖ ប្រជាជនធម្មតា លែងធ្វើអី ។

ធានី ៖ លែងធ្វើទាហានធ្វើអីលែង?

នាក់ ៖ អត់ទេ អត់លែងធ្វើអី ដល់ចូលជំរំលែងធ្វើអីស្អីក៏អត់ធ្វើៗដែរ ។

ធានី ៖ ម៉េចចឹងតា?

នាក់ ៖ អត់ ។

ធានី ៖ អត់ចង់ធ្វើ?

នាក់ ៖ កាំភ្លើងអីខ្ញុំមិន ។

ធានី ៖ គេឲ្យកាន់ដែរ?

នាក់ ៖ តាំងពីតូចមកគេឲ្យកាន់ ប៉ុនខ្ញុំថាមិនហ៊ានកាន់ទេ ។

ធានី ៖ ម៉េចចឹងតា?

នាក់ ៖ ខ្លាច ។

ធានី ៖ ខ្លាចអី?

នាក់ ៖ ខ្លាច មិនហ៊ាន រហូតទល់មកសព្វថ្ងៃ មិនដែលកាន់អាវុធកាន់អី ។

ធានី ៖ ចឹងដូចថាលោកតាធ្លាប់ស្គាល់មេដឹកនាំអស់ហ្នឹង មេដឹកនាំខ្មែរក្រហមកាលពីមុន ធ្លាប់ស្គាល់ធ្លាប់ឃើញមុខធ្លាប់ឃើញស្គាល់?

នាក់ ៖ ខ្មែរ មេខ្មែរក្រហមវាដំណាក់មួយៗវាផ្លាស់ប្តូរច្រើនណាស់ អាហ្នឹងមេធំហ្នឹងតាអៀង សារី តាសំផន អាហ្នឹងនៅអៀង សារី នៅជំរំផ្សេងពីជំរំ៨៥ ។

ធានី ៖ នៅជំរំណា?

នាក់ ៖ នៅជំរំចូលហួសនៅក្នុងដីថៃដែរ ប៉ុនជំរំវាផ្សេង ។

ធានី ៖ ហៅជំរំដ-៥ អីដប៉ុន្មាន?

នាក់ ៖ អៀង វុធ កូនតាអៀង សារីនោះ អាហ្នឹងគេអ្នកទាក់ទងថៃ ត្រូវជាអន្តរត្រូវជាអីហ្នឹងយកមកចិញ្ចឹមប្រជាជនណា អៀង វុធហ្នឹង។ ហើយកំប៉េចកំប៉ុក ខ្ញុំអត់សូវដឹងទេ។

ធានី ៖ ចឹងអ៊ី! នៅក្នុងសម័យខ្មែរក្រហមលោកតាស្គាល់ប្រធានភូមិភាគ ដែលលោកតារស់នៅទេ?

នាក់ ៖ អត់ទេ។

ធានី ៖ អត់ស្គាល់?

នាក់ ៖ អត់ទេ។

ធានី ៖ សូម្បីតែគណៈតំបន់ក៏អត់ស្គាល់?

នាក់ ៖ អត់ទេ ព្រោះខ្ញុំមិនសូវរវីរវល់ចឹង។

ធានី ៖ រវីរវល់ចឹង។ និយាយទៅតាំងពីលោកតាបានចូលរបបខ្មែរក្រហមអីចឹងមក លោកតាដែលធ្លាប់ជួយអ្នកណាឲ្យរួចជីវិត ឬក៏ធ្លាប់ផ្តល់ជាចំណីអាហារដល់អ្នកណាគេទេ?

នាក់ ៖ មាន។

ធានី ៖ អ្នកណាគេខ្លះដែរលោកតា?

នាក់ ៖ មកនៅភ្នំពេញយាយ២នាក់ មិនដឹងស្លាប់នៅ ប៉ុនប្រុសនៅ ប្រុសគេហៅថៅហួរវ៉ាង ដួងអ៊ី!គង់ សំអុល។

ធានី ៖ គង់ សំអុល។ លោកតាជួយគាត់?

នាក់ ៖ ខ្ញុំជួយគាត់ ជួយចេះ បងស្រីគាត់នៅជាមួយខ្ញុំៗគាត់ថាយកប្អូនខ្ញុំមកផង ប្អូនខ្ញុំធ្វើគង់សីជួយលាក់ឲ្យខ្ញុំផង។ ហើយខ្ញុំក៏ជួយលាក់ៗចឹង ដល់នេះឪគណៈសហករណ៍ឈ្មោះណេង ឈ្មោះតាជួងៗ «មើលតា សុំកម្លាំងមួយមក» ដល់នេះខ្ញុំថា«ពួងឯងដាំដើមគ ញុកត្រចៀក ញុកមាត់បិទភ្នែកកុំឲ្យឃើញ កុំឲ្យព្រុកុំឲ្យនិយាយបានរស់ណា» ខ្ញុំបង្ហាញផ្លូវចឹងណា។

ធានី ៖ ប្រាប់អ្នកណាគេ ប្រាប់តាគង់ សំអុលហ្នឹង?

នាក់ ៖ ប្រាប់ គង់ សំអុលហ្នឹង។

ធានី ៖ ហើយបងស្រីគាត់?

នាក់ ៖ បងស្រីគាត់នៅជាមួយខ្ញុំមួយ គាត់នៅដេរនៅពេទ្យមួយ។

ធានី ៖ ចឹងបងស្រីគាត់មាន២?

នាក់ ៖ ២។

ធានី ៖ នៅលោកតាមួយ នៅលោកតា?

នាក់ ៖ នៅហ្នឹងខ្ញុំ មើលកូនខ្ញុំ ហើយនៅជេរនៅពេទ្យនោះបងយាយហ្នឹង ហើយប៉ុនដូចនៅជាមួយខ្ញុំ ។

ធានី ៖ ចុះលោកតា គង់ សំអុលហ្នឹង មកនៅណាវិញ?

នាក់ ៖ គង់ សំអុលហ្នឹង ដល់នេះមកនៅជាមួយឪពុកគណៈសហករណ៍ ចាយវាយនេះ ដល់ឡាន យួនចូលមកគាត់ឡើងកាប៉ាល់ហោះទៅភ្នំពេញទៅ ។

ធានី ៖ អូ! ចាយវាយហ្នឹងគណៈសហករណ៍?

នាក់ ៖ មិនទេ ។

ធានី ៖ ឪពុក?

នាក់ ៖ ឪពុកគណៈសហករណ៍ ដូចដាំបន្លែ ។

ធានី ៖ ដែលថាលោកតាថាមិញថាឲ្យដាំដើមគរពេលហ្នឹង?

នាក់ ៖ ហ្នឹងៗ ។

ធានី ៖ លោកតាប្រាប់គាត់ឲ្យដាំដើមគរហ្នឹង ដើម្បីជួយលាក់គង់ សំអុលហ្នឹង?

នាក់ ៖ ជួយលាក់គង់ សំអុល ខ្ញុំប្រាប់គង់ សំអុលហ្នឹង ថាកុំឲ្យពួមាត់ពួករឲ្យសោះ ហ្នឹងរស់ បើថា នេះគេស្រាវជ្រាវយកវៃចោល ។ ហើយខ្ញុំជួយយាយហ្នឹង២នាក់ ហើយគង់សំអុលម្នាក់ ហើយគិតទៅវាអានេះជួយទៅបានបុណ្យទៅចុះ យើងក៏រួចខ្លួន ។ ប៉ុនកូនខ្ញុំនៅភ្នំពេញហ្នឹងពីឆ្នាំ ទៅកូនខ្ញុំអាមួយទៅរៀនបេអ៊ីមនៅកំបូលនោះ គាត់ទូរស័ព្ទឲ្យទៅ២ដង ។

ធានី ៖ អូ! ចឹងបានជួយលោកតាដែរ?

នាក់ ៖ អត់ទេ អត់ទាន់បានជួបទេ ។ ទូរស័ព្ទ២ដងឲ្យទៅ កូនខ្ញុំអត់ហ៊ានទៅ ។

ធានី ៖ ម៉េចចឹង?

នាក់ ៖ អត់ហ៊ាន ហើយដល់កូនមួយនៅភ្នំពេញនេះទៀត ដល់ប្រាប់ថា ឥឡូវឪពុកខ្ញុំឈ្មោះនាក់ហ្នឹង កាលដែល លោកដែល ។

ធានី ៖ នាក់ ហាន?

នាក់ ៖ ហ្នឹងហើយ ហាន នាក់ ។ កាលដែលលោកនៅជាខ្មែរក្រហមហ្នឹង គាត់យកទៅទុកនៅធ្វើដាំ បន្លែ នៅចាយវាយហ្នឹង ហើយបានគាត់ថាអ៊ើ! ប៉ុនអត់បានមកលេងគាត់ទេ ។

ធានី ៖ ចឹងលោកតាយកអ្នកយកលោក គង់ សំអុល ទៅនៅដាំបន្លែជាមួយលោកផ្ទាល់?

នាក់ ៖ គេសុំ ។

ធានី ៖ គេសុំម៉េច?

នាក់ ៖ ដំបូងនៅជាមួយខ្ញុំ ដល់គេឪពុកគណសហករណ៍ហ្នឹង ដល់នេះសុំកម្លាំងមួយមក ខ្ញុំប្រាប់ ។

ធានី ៖ ឲ្យគាត់ទៅៗ ប៉ុន្តែសូមឲ្យលោកមាត់កុំឲ្យប្រាប់គេ?

នាក់ ៖ ហ្នឹងៗហើយ ។

ធានី ៖ ចឹងលោកគង់សំអុលហ្នឹង ត្រូវបានគាត់ធ្វើការជាមួយលោកតាផង បន្ទាប់មកធ្វើជាមួយឪពុកគណៈសហករណ៍ហ្នឹងផង?

នាក់ ៖ ហ្នឹងៗ ធ្វើជាមួយខ្ញុំតិចទេ គ្រាន់គាត់បង្រៀន គាត់ជាគង់សីខាងកសិកម្ម គាត់ដាំបន្លែ គាត់ថាតាឯងដីករណ្ដៅ៣ បន្លែដាំយកមើម ដាំយកស្លឹក ដាំយកផ្លែ ដីករណ្ដៅ៣គាត់ធ្វើឲ្យមើល គាត់បង្រៀន បានយើងចេះអី ។ ដាំយកផ្លែ ដាំយកស្លឹក ដាំយកមើម ។ មើមដូចដំឡូងមី ផ្លែដូចពោត ។

ធានី ៖ តែចឹងគាត់ធ្លាប់ៗហៅអញ្ជើញកូនលោកតាទៅជួបដែរ ប៉ុន្តែអត់ទៅ អត់ហ៊ានទៅ?

នាក់ ៖ អត់ហ៊ានទៅ ។

ធានី ៖ ខ្លាចតែ?

នាក់ ៖ កូនខ្ញុំទៅរៀនប៉េអ៊ីមនៅកំបូលប៉ុន្នាន ។

ធានី ៖ ម៉េចបានគាត់ដឹងថាកូនលោកនៅហ្នឹង អូ!កូនលោកតាទៅជួបម្ដងហើយ?

នាក់ ៖ ទេ! អាហ្នឹង អាប្អូនទៅរៀនប៉េអ៊ីម អាបងអត់ទេ វានៅធ្វើការនៅអគ្គរក្សហ៊ុន សែនសម្រាប់តែងតាំងតុតែងទៅកន្លែងៗណា ។

ធានីៈ កូនលោកតារាល់ថ្ងៃហ្នឹង?

នាក់ ៖ ហ្នឹងហើយ វាថាត្រូវទោសម្ដោធន៍កន្លែងណា វាហៅគ្នាវាទៅតុបតែងកម្មវិធីហ្នឹង ។

ធានី ៖ ហើយដល់ពេលហើយ គេធ្លាប់ គាត់បានចូលទៅជួបលោកតាគង់ សំអុល និយាយជាមួយរឿងថា?

នាក់ ៖ ជួប ហ្នឹងហើយជួបកូនខ្ញុំ ជួបគាត់ហ្នឹងបានគាត់ថា *“អី!មិនបានទៅលេងគាត់ទេ រវល់ណាស់មិនបានទៅជួបគាត់ទេ”* ។

ធានី ៖ ពេលណាលោកតាអញ្ជើញទៅលេង?

នាក់ ៖ អូ! មិនទៅ ។

ធានី ៖ ម៉េចចឹង?

នាក់' ៖ មិនទៅ ។

ធានី ៖ អត់ចូលចិត្ត?

នាក់ : (សើច) ។

ធានី : ចឹងមានអ្នកផ្សេងទៀតទេលោកតា?

នាក់ : បាទ!

ធានី : មានអ្នកផ្សេងទៀតទេ អត់ទេ?

នាក់ : អត់ទេ ។

ធានី : មានតែគាត់ហ្នឹងមួយ ហើយលោកតាចេះបិទរហូតដល់?

នាក់ : បិទរហូតរស់ ក្រៅពីហ្នឹងខ្ញុំអត់ហ៊ានកម្រើកទេ ។

ធានី : ចុះអ្នកឲ្យជាចំណីអាហារអីក៏អត់មានដែរ?

នាក់ : អត់ទេ ។

ធានី : មានតែជួយឲ្យរួចជីវិតចឹង?

នាក់ : បាទ!

ធានី : ចឹងគេសុំយកទៅសម្លាប់ ឬក៏សុំ?

នាក់ : សុំយកទៅធ្វើការ ។

ធានី : សុំធ្វើការ ប៉ុន្តែលោកតាបានប្រាប់ឪគាត់ហ្នឹងថាកុំឲ្យយកគាត់?

នាក់ : ទេ!

ធានី : ប្រាប់គង់សំអុលហ្នឹង?

នាក់ : គង់ សំអុលហ្នឹង ។

ធានី : ថាត្រូវចេះបិទមាត់ ចេះកអីចឹង?

នាក់ : ហ្នឹងហើយកុំពូមាត់ពុកអីបាន ។

ធានី : ហើយលោកតាបានប្រាប់តាំងពីដំបូងថាអ្នកស្រែចំការអីចឹង ឬមួយយ៉ាងម៉េច?

នាក់ : ទេ! ជាអ្នក ។

ធានី : អ្នកផ្សេងហ្នឹងគាត់ដឹងដែរ ថាលោកតាគង់សំអុលធ្វើអី?

នាក់ : អត់ទេ ។

ធានី : អត់ទេ មានតែលោកតាដែរដឹង?

នាក់ : មានតែខ្ញុំទេដឹង ព្រោះអីបងគាត់អ្នកប្រាប់ខ្ញុំឲ្យទៅសុំគេមក ហើយខ្ញុំសុំមកបានប៉ុន្មានថ្ងៃហ្នឹង ។

ធានី : គេសុំផ្សេងទៅទៀត?

នាក់ : ឪពុកគណសហករណ៍ហ្នឹងសុំផ្សេងទៀត បានខ្ញុំប្រាប់ថា "កុំពុមាត់ ពុក៏តែពុមាត់ពុកអត់រស់ទេ" ព្រោះគាត់ធ្វើគណៈ... ។

ធានី : បងប្អូនគាត់៣នាក់នៅក្នុងសហករណ៍ចាមរអាលហ្នឹងតែមួយទេ?

នាក់ : ហ្នឹងៗហើយ ហើយយាយមួយនៅមើលកូនឲ្យខ្ញុំ ហើយយាយមួយទៅដេរ ហើយតា គង់ សំអុល ហ្នឹងគាត់មកនៅហ្នឹងបានប៉ុន្មានថ្ងៃហ្នឹង ក៏គេសុំខ្ញុំឲ្យទៅ ប៉ុនប្រាប់គាត់លាក់មាត់លាក់កទៅបានរស់ ។

ធានី : ចុះលោកតារកនឹកមើល ពេទ្យនៅចាមរអាកហ្នឹង ក្រៅពីពេទ្យដែលលោកតានិយាយមានឈ្មោះអីគេ?

នាក់ : ទេ!

ធានី : ដែលមានកូនស្រី កូន៤នាក់ កូនស្រី២ ប្រុស២ ប៉ុន្តែប្រុសក្រោយហ្នឹងកូនងាំ ។

នាក់ : ភ្លេចអស់ហើយ ខ្ញុំភ្លេច មនុស្សឃើញស្គាល់ទាំងអស់ ប៉ុនភ្លេចឈ្មោះ ។

ធានី : តែមានពេទ្យហ្នឹងអត់ ពេទ្យហ្នឹងរៀនធំដែរ រៀនស្ងួតតិច?

នាក់ : ពិបាកសន្និដ្ឋានណាស់ខ្ញុំមិន ។

ធានី : មិនចាំ ព្រោះពុថាពេទ្យហ្នឹងគាត់និយាយថា កូនគាត់ថាបានជួយសង្គ្រោះបងស្រីគាត់ដែរ ឲ្យរួចជីវិតចឹងដែរ ថានៅចាមរអាលដូចគ្នា បានចង់សួរលោកតាដែលធ្លាប់ស្គាល់ពេទ្យហ្នឹងអត់? ដែលគាត់ធ្វើពេទ្យ?

នាក់ : ខ្ញុំមិនៗសូវស្គាល់ទេ ភ្លេចៗ អានេះភ្លេចឈ្មោះ បើយូរពេកហើយយូរអង្វែងអានេះនិយាយពីភ្លេច ។ ខ្ញុំគ្រាន់មនុស្សនៅនឹងភូមិនឹងក៏ខ្ញុំភ្លេចឈ្មោះដែរ ប៉ុនឃើញរូបខ្ញុំស្គាល់ ប៉ុនឈ្មោះភ្លេច វាវង្វេងវង្វាន់ទៅវា៧៩ហើយ ។

ធានី : ចុះលោកតាតាំងពីមុនមកដល់ឥឡូវ លោកតាដែលធ្លាប់ទៅលេងស្រុកកំណើតទេ?

នាក់ : ដែរ ។

ធានី : ធ្លាប់ទៅលេងប៉ុន្មានដងទៅ?

នាក់ : ទៅ២ដង ៣ដង បងខ្ញុំស្លាប់ ខ្ញុំទើបទៅពីឆ្នាំទៅមួយ ។

ធានី : ស្រុកកំណើត២ទៅ៣ដង កាលពេលទៅលើកដំបូងនៅឆ្នាំប៉ុន្មាន?

នាក់ : ទេ! អាហ្នឹងខ្ញុំនិយាយពីលើកក្រោយចុះ ទៅពីរវាងពីឆ្នាំទៅ ឆ្នាំទៅមួយ ។

ធានី : តែលើកដំបូងលោកតាទៅ?

នាក់ : អាលើកដំបូងនោះយូរហើយ ។

ធានី ៖ ឆ្នាំណាដែរ?

នាក់ ៖ តាំងពីឆ្នាំ អាហ្នឹងនៅគ្រួសារខ្ញុំមិនទាន់ស្លាប់ ទៅជាមួយគ្នាទាំងអស់ វាយូរពេកហើយចៅ ភ្លេចអស់ហើយ ។

ធានី ៖ កាលហ្នឹងលោកតាចូលសម័យខ្មែរក្រហមនៅ?

នាក់ ៖ នៅទេ ។

ធានី ៖ ទៅលេងស្រុកហ្នឹង?

នាក់ ៖ ហ្នឹងហើយ ។

ធានី ៖ ដល់ពេលក្រោយខ្មែរក្រហម លោកតាដែលធ្លាប់ទៅលេងទៀតទេ?

នាក់ ៖ អត់ដែលទៅ ។

ធានី ៖ ដល់ពេលទៅទើបតឡូវ២-៣ឆ្នាំក្រោយនេះទេ?

នាក់ ៖ ហ្នឹងហើយ បងខ្ញុំស្លាប់អាហ្នឹងខ្ញុំទៅ ។

ធានី ៖ ទៅលេង?

នាក់ ៖ ទៅ ។

ធានី ៖ លោកតាទៅដំបូងមានអារម្មណ៍ម៉េចដែរ?

នាក់ ៖ ទេ! ទៅដល់មានអារម្មណ៍ថាទេ! ដីស្រែគេពុះចែកគ្នាម្នាក់១០អា១ អស់រលីង ហើយស្រែខ្ញុំគេចែកគ្នាអស់ ខ្ញុំគ្មានបានអីហ្នឹងគេ គេអត់ឲ្យ គេថាយើងគ្មានកម្មសិទ្ធិអីមកវែកញែករឿងដី ធ្លីអីទេ ។

ធានី ៖ គេប្រាប់ចឹងតា?

នាក់ ៖ បាទ!

ធានី ៖ តែប៉ុនហ្នឹងតានោះ?

នាក់ ៖ បាទ!

ធានី ៖ ចុះម៉េចបានលោកតាអត់នៅស្រុកកំណើត សុខចិត្តមកនៅនេះ?

នាក់ ៖ ហ៊ើ! ចុះគេថាអ្នករសាត់សែនត្រែងចេះដើរផ្សងព្រេងទៅ ។

ធានី ៖ អឺ! ដើរផ្សងព្រេង?

នាក់ ៖ បាទ!

ធានី ៖ ចឹងលោកតាមានអីចង់សួរខ្ញុំវិញទេ ឬក៏ចង់សំណូមពរអី?

នាក់ ៖ ទេ! ខ្ញុំចង់សួរថាចេះដែលយករបាយការណ៍ហ្នឹង យកទៅដាក់ខាងណាវិញ?

ធានី ៖ ចេះលោកតា ពួកខ្ញុំចុះមកនេះគ្រាន់ចង់ដឹងពីប្រវត្តិរបស់លោកតាហ្នឹង យកមកសរសេរជាសៀវភៅៗសម្រាប់ឲ្យក្មេងៗ ឬអ្នកស្រាវជ្រាវផ្សេងៗគាត់ចង់ចឹងសិក្សារៀនសូត្រពីប្រវត្តិសាស្ត្រ ដែលលោកតាបានឆ្លងកាត់ខ្លួនឯងហ្នឹង ទៅឲ្យក្មេងក្រោយបានដឹងបានព្ញអីចឹង ។ ហើយរឿងអស់ហ្នឹងក្មេងៗយកមកសិក្សាបន្តទៀត អូ!តាមពិតកាលសម័យហ្នឹងវាយ៉ាងម៉េច មានការលំបាកម៉េចខ្លះ មានការរស់នៅប្រជាជនរស់នៅដូចវាយ៉ាងម៉េច ដូចលោកតាផ្ទាល់រត់ ពីជំរំមួយទៅជំរំមួយហើយមានការលំបាកយ៉ាងម៉េច រត់គេចចេញពីសង្គ្រាម រត់គេចចេញពី អី ចឹងណាលោកតា ។

នាក់ ៖ បាទៗ ។

ធានី ៖ ហើយការរស់នៅវាលំបាកយ៉ាងម៉េចខ្លះ ចឹងដើម្បីឲ្យក្មេងៗក្រោយបានដឹង ហ៎!សម័យមុនវាមិនមែនជាការងាយស្រួលដូចសម័យឥឡូវ មានហូបមានចុកមានអីរស់នៅស្រួលបួលចឹងណា៎លោកតាណា៎ ។

នាក់ ៖ បាទៗ ។

ធានី ៖ ព្រោះអី ស្អាលទោសលោកតា យើងទាំងខ្ញុំទាំងគេអី យើងមិនទៀងទេអាយុយើង បើសិនយើងថែរក្សាដូចការនិយាយប្រាប់របស់ខ្ញុំ ហើយខ្ញុំយកមកធ្វើជាសៀវភៅវាអាចទុកបានយូរជាងអាយុដែលយើងនៅរស់ចឹង អាចតៗក្មេងៗក្រោយបានដឹងតាណា៎ ។

នាក់ ៖ បាទៗ ។

ធានី ៖ ចឹងខ្ញុំសុំយកទៅធ្វើជាចឹង ។ មានចង់អីសួរទៀតតា ចង់សំណូមពរអី ឬចង់អី?

នាក់ ៖ ទេ! ខ្ញុំមិនចង់សំណូមពរអី មិនចង់សួរអីទៀតទេ គ្រាន់ចង់ដឹងតែប៉ុនហ្នឹង ដែលយកនេះយកទៅ ។

ធានី ៖ ធ្វើជាសៀវភៅ ។

នាក់ ៖ ទៅជាសៀវភៅ មិនមែនយកទៅសម្រាប់កកាយ នៅអារឿងរ៉ាវចាស់ពីដើមមកយ៉ាងម៉េចៗ ។

ធានី ៖ អូ! ចឹងលោកតាដែលធ្លាប់ព្ញរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

នាក់ ៖ លោកឌុចហ្នឹង ។

ធានី ៖ ចា៎! ធ្លាប់កាត់ទោសឌុច កាត់ទោសអៀង សារី ខៀវ សំផន ធ្លាប់ព្ញទេ?

នាក់ ៖ ទេ! ឥឡូវហ្នឹងឃើញគេបញ្ចាំងក្នុងទូរទស្សន៍ ប៉ុនឥឡូវ ។

ធានី ៖ គេកាត់ទោស?

នាក់ ៖ គេមិនទាន់កាត់ទេ ហើយកាត់ម៉េចបើសុទ្ធតែខ្មែរក្រហមទាំងអស់ ។

ធានី ៖ អត់ទេ ចង់និយាយថាកាត់ទោសអ្នកធំៗអស់ហ្នឹង លោកតាដឹងដែរ ដឹងថាមានគេកាត់ទោសពួកគាត់?

នាក់ ៖ មិនទាន់កាត់ទេ ។

ធានី ៖ ប៉ុន្តែដឹងថាមាន គេចាប់គាត់យកទៅដាក់ឃុំ?

នាក់ ៖ គេចាប់យកទៅដាក់ឃុំឃាំង ។

ធានី ៖ លោកតាយល់ថាម៉េចដែរ ចំពោះខាងតុលាការដែលគេចាប់គាត់យកទៅដាក់ហ្នឹង?

នាក់ ៖ ទេ! ខ្ញុំឆ្ងល់យល់មិនដល់ ព្រោះអីប៉ាន់ស្មានវាមិនត្រូវ ថាវាមិនត្រូវពីព្រោះអីវាត្រឡប់កាប់ ផ្ងារ ។

ធានី ៖ ត្រឡប់កាប់ផ្ងារម៉េចតា?

នាក់ ៖ ត្រឡប់កាប់ផ្ងារពីសង្គមមួយទៅសង្គមមួយយើងថាត្រូវ ។

ធានី ៖ គេថាខុសចឹង?

នាក់ ៖ គេថាខុស យើងថាខុស គេថាត្រូវ ។

ធានី ៖ ចុះចំពោះចិត្តលោកតាៗគិតថា តើវាសមស្របអត់ចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងប៉ុន្មាន នាក់ដែលតុលាការកាត់ទោសរាល់ថ្ងៃហ្នឹង?

នាក់ ៖ ទេ! អានេះបើតាមខ្ញុំធ្លាប់នៅរួមរស់ធ្លាប់ដឹងធ្លាប់ឮ អានេះគេទាមទារកាត់វាត្រូវរបស់គេហើយ ប៉ុនត្រង់ច្បាប់មិនដឹងយ៉ាងណា ។

ធានី ៖ ច្បាប់មិនដឹងយ៉ាងណា ច្បាប់អីគេ ច្បាប់មនុស្ស ចាប់ទូទៅ ឬច្បាប់ជាជាតិយើង?

នាក់ ៖ ច្បាប់ដែលជាតិយើង មិនដឹងគេគិតយ៉ាងណាយ៉ាងណែ ខ្ញុំមិនសូវដឹងគេទេ ។

ធានី ៖ ប៉ុន្តែដឹងថាកាត់ទោសហ្នឹងត្រូវ?

នាក់ ៖ បាទ! បើមិនត្រូវគេមិនចាប់យើងឃុំឃាំងទេ ព្រោះគេចោទយើងជាអ្នកដាក់គុកនៅព្រៃសហ្នឹង វាភាប់សិបមុខ ។

ធានី ៖ ឌុចហ្នឹងតា?

នាក់ ៖ បាទ! ហើយដល់ ។

ធានី ៖ ចុះក្រៅពីតាឌុចនោះ?

នាក់ ៖ ហើយដល់តាឌុចឆ្លើយ គាត់ថាខ្ញុំមិនមានវែដ្ឋិប្រាំធាក់បងប្អូន មានគេផ្សេងគេវែដ្ឋិប្រាំធាក់ ខ្ញុំគ្រាន់មាននាទីជាគ្រប់គ្រងទេ ។

ធានី ៖ លោកតាបានមើល?

នាក់ ៖ គាត់ឆ្លើយផុយរបស់គាត់ ។

ធានី ៖ លោកតាយល់យ៉ាងម៉េចដែរចំពោះចម្លើយហ្នឹង?

នាក់ ៖ បាទ! ខ្ញុំពិបាកថាណាស់ ដូចខ្ញុំប្រាប់ចៅឯងថាវាជំនាន់នេះវាចេះៗនិយាយមិនកើត ។

ធានី ៖ ប៉ុន្តែលោកតានិយាយទៅដូចលោកតាធ្លាប់ជាអ្នកធ្លាប់នៅក្នុងរបបហ្នឹងដែរ ដឹងរឿងការកាប់សម្លាប់អីមនុស្សម្នាក់ពីម្នាក់ទៅម្នាក់អីចឹងមាន១៧អីស្លាប់ច្រើនអីចឹង ។ ចំពោះចិត្តលោកតាផ្ទាល់ដែលលោកតាបានឃើញបានឮ ដឹងរឿងអស់ហ្នឹងផ្ទាល់ អាហ្នឹងលោកតាបានឃើញឆ្អែតកាត់ផ្ទាល់ អ្នកខ្លះបានត្រឹមតែគេនិយាយអីចឹង ។ ថាដូចខ្ញុំក្មេងៗបានត្រឹមតែនិយាយ បានត្រឹមតែឮទេ អត់ដឹងទេ ចឹងដូចថាលោកតាបានឃើញបានឮផ្ទាល់ចឹង តើលោកតាយល់យ៉ាងម៉េចដែរចំពោះការកាត់ទោសមេដឹកនាំទាំងអស់ហ្នឹង ក៏ដូចជាឌុចផ្ទាល់ ក៏ដូចជាមេដឹកនាំ៤នាក់ទៀត?

នាក់ ៖ (សើច) ខ្ញុំរកសន្និដ្ឋានមិនកើតទេ ។

ធានី ៖ អាហ្នឹងជារឿងរបស់គេ ឬយ៉ាងម៉េច?

នាក់ ៖ ជារឿងរបស់គេ ឥឡូវយើងទៅអះអាងថាដឹង ថា ។

ធានី ៖ ចិត្តលោកផ្ទាល់គិតថា តុលាការនឹងអាចរកយុត្តិធម៌ឲ្យប្រជាជនដែលស្លាប់ទាំងប៉ុន្មាន ដែលលោកបានដឹងបានទេមើលទៅ?

នាក់ ៖ ឥឡូវនេះគេកំពុងស្រាវជ្រាវពីកន្លែងមួយទៅកន្លែងមួយ ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ដែលយកម៉ែឪបងប្អូនកូនចៅយកទៅសម្លាប់ គេឡើងមកសើរើឲ្យកាត់ទោសពួកខ្មែរក្រហម ព្រោះអីកាប់សម្លាប់កូនប្រពន្ធគេអស់ប៉ុននេះៗទៅ ។ អាហ្នឹងគេមានឡើងតវ៉ាចឹងតើ ហើយក៏ប៉ុនរឿងហ្នឹងមិនដឹងយ៉ាងម៉េច ខ្ញុំមិនសូវដឹងទេ ខ្ញុំមិនហ៊ាន ។

ធានី ៖ និយាយថាម៉េច?

នាក់ ៖ និយាយថាឥឡូវឈ្មោះតាឌុចហ្នឹង បានយកប្ដីគាត់ទៅឃុំឃាំងទៅកាប់សម្លាប់ចាប់ចោលអស់ រលីង គេឡើងៗ ។

ធានី ៖ អូ! លោកតាបានមើលដែរ?

នាក់ ៖ អាហ្នឹងហើយ ខ្ញុំមើលទូរទស្សន៍ ប៉ុនត្រង់ពិតមិនពិតខ្ញុំមិនដឹងទេ ។

ធានី ៖ តែចិត្តលោកផ្ទាល់ លោកតាគិតម៉េច គិតថាតុលាការហ្នឹងអាចរកយុត្តិធម៌ឲ្យអ្នកទាំងអស់ហ្នឹងបាន?

នាក់ ៈ  គេរកឲ្យប៉ុនមិនឆាយ ។

ធានី ៈ  មិនឆាយ?

នាក់ ៈ  មិនឆាយ?

ធានី ៈ  ហេតុអីទៅតា?

នាក់ ៈ  ហេតុអីបើមិនឆាយរកឆាប់ទេ យូរ ។

ធានី ៈ  យូរ?

នាក់ ៈ  យូរ ។

ធានី ៈ  ត្រូវការចំណាយពេលច្រើនតិចតា ប៉ុន្តែហ្នឹងដឹងនឹងបាន?

នាក់ ៈ  អឺ!

ធានី ៈ  លោកតាគិតបានវែងឆ្ងាយ ។

នាក់ ៈ  បែបដល់លុយច្រើនបានចប់ បើលុយតិចតួចមិនចប់ទេ ។

ធានី ៈ  លោកតាគិតចឹង ។ ចឹងលោកតាដូចជាទាក់ទងហ្នឹងការផ្សះផ្សាអី លោកតាយល់ពាក្យហ្នឹងទេ ផ្សះផ្សា ការត្រូវ ការធ្វើឲ្យត្រូវរ៉ូវគ្នារវាងមនុស្សទៅមនុស្សអីចឹង?

នាក់ ៈ  ទេ! ពួកអាហ្នឹងវាមិនឆាយផ្សះផ្សាទេ ។

ធានី ៈ  ម៉េចចឹងតា?

នាក់ ៈ  ចុះគេចោទពេញហឹង ។

ធានី ៈ  ពេញដឹង?

នាក់ ៈ  ហ្នឹងហើយ ឥឡូវបើថាខាងរដ្ឋាភិបាលយើងចោទថាតាខុចហ្នឹងជាអ្នក ។

ធានី ៈ  មិនមែនទេ មិនមែនទាក់ទងហ្នឹងគាត់ហ្នឹងទេ ដូចថាប្រជាជនយើង ដូចថាអ្នកផ្សេងៗទៀត មិនមែនគាត់ៗជាអ្នកដឹកនាំជាន់ខ្ពស់ ចឹងគាត់មានការទទួលខុសត្រូវច្រើនផ្នែក ដូចថាវាខ្ពស់ មុខងារធំ តំណែងធំយើងមិនបាច់និយាយទេ ព្រោះអាហ្នឹងរឿងរបស់តុលាការណា ។ តែ យើងចង់និយាយពីប្រជាជនដែលរស់នៅក្នុងភូមិជាមួយគ្នារាល់ថ្ងៃ ។ ដូចថាតើលោកតាអាច គិតថាអាចទៅរួចអត់ចំពោះការផ្សះផ្សាហ្នឹង រវាងខ្មែរក្រហម ជាមួយនឹងប្រជាជនធម្មតា ឬក៏អ្នករងគ្រោះនៅសម័យហ្នឹងអីចឹង?

នាក់ ៈ  (សើច) ខ្ញុំមិនហ៊ាននិយាយទេ ។

ធានី ៈ  ម៉េចចឹងតា?

នាក់ ៈ  វាពិបាកនិយាយណាស់ ។

ធានី ៖ ពិបាកនិយាយ?

នាក់ ៖ បាទ!

ធានី ៖ អត់ដឹង គិតថាអាចទៅរួចអត់មើលទៅ ផ្សះផ្សាហ្នឹងអាចធ្វើកើតអត់រវាងប្រជាជនយើងជាមួយនឹងខ្មែរក្រហម ដូចថាគាត់ជាអ្នកតូចតាច គាត់មិនបានទទួលខុសត្រូវ ដូចមិនចង់ធ្វើ ឬក៏មិនមានចិត្តចង់ធ្វើ ឬក៏ធ្វើដោយចិត្តឯងខ្វះតិចតួច ដូចអន់ចិត្តហ្នឹងអ្នកណាអីចឹង?

នាក់ ៖ ខ្ញុំមិនហ៊ានសន្និដ្ឋានទេ ពីព្រោះអីខ្ញុំចេះវាមិនដល់ និយាយតែម៉ាត់ ។

ធានី ៖ ចឹងលោកតាពាល់ថ្ងៃលោកតាធ្វើជាអាចារ្យវត្ត ឬនៅផ្ទះធម្មតា?

នាក់ ៖ ខ្ញុំធ្វើអាចារ្យភូមិ ។

ធានី ៖ អាចារ្យភូមិ?

នាក់ ៖ បាទ!

ធានី ៖ អូ! អាចារ្យភូមិយើង?

នាក់ ៖ បាទ!

ធានី ៖ កាន់ព្រះពុទ្ធសាសនាដដែល?

នាក់ ៖ បាទ! ថ្ងៃសីលខ្ញុំនិមន្តលោកមកឲ្យយាយៗសុំសីល ។

ធានី ៖ នៅកន្លែងណាវិញ?

នាក់ ៖ នៅសាលាខ្ញុំធំមួយល្វឹងល្វើយ ។

ធានី ៖ អូ! នៅខាងមុខផ្លូវហ្នឹងលោកតា?

នាក់ ៖ ហ្នឹងហើយដែលមានបាំងមាត់ទ្វារហ្នឹង ។

ធានី ៖ ចឹងលោកតាធ្វើជាអាចារ្យ ហើយហ្នឹងនៅផ្ទះ?

នាក់ ៖ បាទ! តែប៉ុនហ្នឹង អត់មានធ្វើអី ។

ធានី ៖ អត់មានធ្វើអីចាំកូនរកស៊ីចិញ្ចឹមវិញ?

នាក់ ៖ បាទ! ទេ!កូននៅ២នាក់លេងនេះ គ្មានបានរកស៊ីចិញ្ចឹមម៉ែឪទេ អាមួយឲ្យទៅរៀននៅភ្នំពេញ អាមួយនៅរៀនវត្តបន្ទាយឆ្មារនេះ អារៀននៅភ្នំពេញនេះប្រឡងជាប់បាក់ឌុប ហើយរកលុយ ឲ្យសិក្សាទៅចូលសកលមិនបានឲ្យបញ្ចូនបងវាឲ្យរៀនកុំព្យូទ័រ និងរៀនអង់គ្លេសបន្ថែម ។

ធានី ៖ ហ្នឹងហើយព្រោះបងគាត់ធ្វើការនៅភ្នំពេញយូរហើយ នៅក្បែរវាំងទៀត ។

នាក់ ៖ ឥឡូវគេជួយៗឲ្យរៀនឲ្យសូត្រទៀត ។

ធានី ៖ តែពួកគាត់ផ្សេងមានគ្រួសារអស់ហើយ ឬក៏នៅដែរ?

នាក់ ៖ ណា?

ធានី ៖ កូនលោកតា មានតែ២ទេ ដែលមិនទាន់មាន ក្រៅពីហ្នឹងមានអស់?

នាក់ ៖ នេះកូនយាយ កូនខ្ញុំមានអស់ ដូចអាមួយនៅ ឈ្មោះអាសំ ប៊ុនធឿននេះ វាទៅធ្វើការនៅ ។

ធានី ៖ សំ ប៊ុនធឿន ។

នាក់ ៖ នៅពេទតម្បាញនេះ ។

ធានី ៖ ពេទតម្បាញ?

នាក់ ៖ បាទ!

ធានី ៖ ស្មានតែអ្នកវិទ្យុ ។ (សើច) ចឹងលោកតាកូនក្រោយនេះ ដែលថាជាមួយយាយ កូន២នាក់ហ្នឹង គឺកូននៅលីវ តូចៗនេះហ្នឹង?

នាក់ ៖ ហ្នឹងហើយ កូននៅលីវ ។

ធានី ៖ កូនជាមួយយាយ?

នាក់ ៖ បាទៗ ។

ធានី ៖ យល់ហើយ លោកតាមានអីទៀត?

នាក់ ៖ អត់ចប់ហើយ ចប់ប៉ុនហ្នឹង ។

ធានី ៖ អរគុណច្រើនលោកតា ។

«ចប់»